# ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា

## ជំពូក ២០

# ការគ្រប់គ្រងបរិស្ថានក្នុងសកម្មភាពមីន

-----------------------------------------------

អគ្គលេខាធិការដ្ឋាន
អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
អគារថ្មីផ្លូវលេខ ២៧៣កែង៥១៦ សង្កាត់ទួលសង្កែ ខណ្ឌទួលគោក រាជធានីភ្នំពេញ
ទូរស័ព្ទលេខ : ០២៣-៨៨៥-៩៤១|០២៣-៨៨១-៤៩២
ទូរសារ : +885-23-881-308
អ៊ីម៉ែល : deth@cmaa.gov.kh
គេហទំព័រ : www.cmaa.gov.kh

## Contents


**ការគ្រប់គ្រងបរិស្ថានក្នុងសកម្មភាពមីន** ..... 3

**សេចក្តីផ្តើម** ..... 3

**១. វិសាលភាព** ..... 5

**២. ឯកសារយោង** ..... 5

**៣. វាក្យស័ព្ទ និងនិយមន័យ** ..... 5

**៤. តម្រូវការទូទៅ** ..... 6

**៥. ការគ្រប់គ្រងបរិស្ថាន** ..... 6

៥១. គោលនយោបាយបរិស្ថាន ..... 6

៥២. ស្វែងយល់អំពីបរិបទបរិស្ថាន ..... 7

៥៣. កំណត់ និងវាយតម្លៃទិដ្ឋភាពបរិស្ថាន ..... 7

៥៤. កំណត់វិធានការការពារ និងកាត់បន្ថយផលប៉ះពាល់បរិស្ថាន ..... 8

៥៥. ការវាយតម្លៃផលប៉ះពាល់បរិស្ថាន ..... 8

៥៦. ការរៀបចំ និងបែងចែកភារកិច្ចនៃប្រតិបត្តិការបោសសម្អាតមីន ..... 9

៥៧. ការអនុវត្តកិច្ចប្រតិបត្តិការ ..... 9

៥៨. ការត្រួតពិនិត្យទិដ្ឋភាពបរិស្ថាន ..... 10

៥៩. ការពិនិត្យ និងការកែលម្អ ..... 10

**៦. ទំនួលខុសត្រូវ និងភារកិច្ច** ..... 11

៦១. ការទទួលខុសត្រូវរបស់អាជ្ញាធរមីន ..... 11

៦២. ការទទួលខុសត្រូវរបស់ប្រតិបត្តិករបោសសម្អាតមីន ..... 11

៦.៣ ការទទួលខុសត្រូវរបស់ម្ចាស់ជំនួយ និងភាគីពាក់ព័ន្ធផ្សេងទៀត ..... 12

ឧបសម្ព័ន្ធ ក: ឯកសារយោង ..... 13

ឧបសម្ព័ន្ធ ខ: គោលការណ៍ណែនាំស្តីពីវិធានការការពារ និងកាត់បន្ថយផលប៉ះពាល់បរិស្ថាន ..... 13

ឧបសម្ព័ន្ធ គ: គោលការណ៍ណែនាំសម្រាប់វាយតម្លៃផលប៉ះពាល់បរិស្ថាន ..... 20

ឧបសម្ព័ន្ធ ឃ: (ព័ត៌មាន (បញ្ជីត្រួតពិនិត្យការគ្រប់គ្រងបរិស្ថាន ..... 23

# ការគ្រប់គ្រងបរិស្ថានក្នុងសកម្មភាពមីន
## សេចក្តីផ្តើម

ការគ្រប់គ្រងបរិស្ថានប្រកបដោយប្រសិទ្ធភាពនៅក្នុងសកម្មភាពមីន គឺជាគោលបំណងសំខាន់របស់អាជ្ញាធរមីន ប្រតិបត្តិករបោសសម្អាតមីន សហគមន៍រងផលប៉ះពាល់ ម្ចាស់ជំនួយ និងភាគីពាក់ព័ន្ធដទៃទៀត។ ការការពារបរិស្ថានទទួលបានការយកចិត្តទុកដាក់យ៉ាងខ្លាំងពីរាជរដ្ឋាភិបាល (ក្រសួង និងមន្ទីរបរិស្ថានខេត្ត) ដោយចាត់ទុកជាអាទិភាពនៃកិច្ចអភិវឌ្ឍ ដើម្បីឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា ។

សកម្មភាពមីន មិនត្រឹមតែធ្វើឱ្យប្រសើរឡើងនូវសុវត្ថិភាព និងសន្តិសុខប្រជាជនប៉ុណ្ណោះទេ ក៏ផ្តល់នូវក្រឡានុវត្តភាពសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ស្របតាមផែនការអភិវឌ្ឍជាតិ និងថ្នាក់ក្រោមជាតិ ក្នុងគោលបំណងកាត់បន្ថយផលប៉ះពាល់សេដ្ឋកិច្ចសង្គម និងបរិស្ថានដោយសារគ្រាប់មីន គ្រាប់បែកចង្កោម និងសំណល់ជាតិផ្ទុះពីសង្គ្រាមផ្សេងទៀត។ សកម្មភាពមីនមានឥទ្ធិពលជាវិជ្ជមានទៅលើបរិស្ថាន ប៉ុន្តែនេះមិនមែនមានន័យថាសកម្មភាពមីនទាំងអស់មិនមានផលប៉ះពាល់អាក្រក់ដល់បរិស្ថាននោះទេ។ ដូច្នេះ ការការពារ និងការកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាន មានសារៈសំខាន់តាមរយៈការគ្រប់គ្រងបរិស្ថានសមស្របដោយយកចិត្តទុកដាក់លើសកម្មភាពជាក់លាក់មួយចំនួន ដែលអនុវត្តដោយប្រតិបត្តិករបោសសម្អាតមីន ធនធានដែលបានយកមកប្រើប្រាស់ និងបរិបទដែលប្រតិបត្តិករបោសសម្អាតមីនកំពុងអនុវត្ត និងប្រើប្រាស់។ ការគ្រប់គ្រងបរិស្ថានក្នុងសកម្មភាពមីនជាការគាំទ្រដល់ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ដែលមានចែងនៅក្នុងគោលបំណងទីប្រាំបី និងគោលដៅទីបួន។

ការគ្រប់គ្រងបរិស្ថានមានគោលបំណងពង្រឹងប្រសិទ្ធភាព និងប្រសិទ្ធផលនៃសកម្មភាពមីន ដើម្បីសម្រេចគោលបំណង និងគោលដៅដែលបានកំណត់។ កង្វះខាតការគ្រប់គ្រងបរិស្ថានក្នុងសកម្មភាពមីន អាចកាត់បន្ថយ ឬរារាំងដល់លទ្ធផលរំពឹងទុកពីប្រតិបត្តិការសកម្មភាពមីន ព្រមទាំងអាចបង្កឱ្យមានផលប៉ះពាល់រយៈពេលវែងនិងខ្លី ដល់បរិយាកាស (ទឹក ដី និងខ្យល់) របស់សហគមន៍ដែលរស់នៅជុំវិញទីតាំងប្រតិបត្តិការ។ បន្ថែមលើនេះ ក៏អាចបង្កគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋ ខូចខាតបរិស្ថាន និងហេដ្ឋារចនាសម្ព័ន្ធនានា ដែលអាចនាំឱ្យមានចំណាត់ការតាមផ្លូវច្បាប់ និងបណ្តឹងទាមទារសំណងផ្សេងៗដែលអាចជាផលលំបាកសម្រាប់ប្រតិបត្តិករបោសសម្អាតមីន។ ផលប៉ះពាល់អវិជ្ជមានទៅលើបរិស្ថាន អាចបង្កឱ្យជាបញ្ហាសង្គម សេដ្ឋកិច្ច និងនយោបាយនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់ផងដែរ។ ដូច្នេះការគ្រប់គ្រងបរិស្ថានទាមទារឱ្យមានដំណោះស្រាយរួមទូលំទូលាយ ដែលអាចវាយតម្លៃផលប៉ះពាល់ផ្សេងៗ និងបង្កើនការយល់ដឹងអំពីការការពារបរិស្ថានដល់ប្រតិបត្តិករបោសសម្អាតមីនទាំងអស់។

អាជ្ញាធរមីន និងប្រតិបត្តិករបោសសម្អាតមីនទទួលខុសត្រូវធានាថា រាល់សកម្មភាពមីនរួមមានការធ្វើផែនការ ការចាត់អាទិភាព ការស្រាវជ្រាវមិនបច្ចេកទេស ការស្រាវជ្រាវបច្ចេកទេស ការបោសសម្អាត និងការកម្ទេចគ្រឿងផ្ទុះ អនុវត្តស្របតាមបទដ្ឋានប្រតិបត្តិការ និងច្បាប់ពាក់ព័ន្ធជាធរមានប្រកបដោយសុវត្ថិភាព ប្រសិទ្ធភាព និងប្រសិទ្ធផលដោយមិនបង្កផលប៉ះពាល់អវិជ្ជមានដល់មនុស្ស សត្វ រុក្ខជាតិ និងកត្តាបរិស្ថានផ្សេងទៀត។ បន្ថែមលើនេះ គួរផ្តោតការយកចិត្តទុកដាក់ទៅលើការបោសសម្អាតដោយប្រើប្រាស់គ្រឿងចក្រ និងការកម្ទេចគ្រាប់ដែលអាចបង្កផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់បរិស្ថាន។ គោលបំណងទូទៅនៃការគ្រប់គ្រងបរិស្ថានក្នុងសកម្មភាពមីន គឺរក្សាស្ថានភាពបរិស្ថានបន្ទាប់ពីបញ្ចប់ប្រតិបត្តិការសកម្មភាពមីនឱ្យមានសភាពស្រដៀងគ្នា ឬប្រសើរឡើងជាងមុន ព្រមទាំងអាចប្រើប្រាស់ដីដែលបោសសម្អាតរួចតាមការគ្រោងទុក។

ការគ្រប់គ្រងបរិស្ថានក្នុងសកម្មភាពមីន មិនគួរជាបន្ទុកនៅក្នុងការងារបោសសម្អាតមីនឡើយ ហើយត្រូវអនុវត្តស្របគ្នាជាមួយនឹងស្តង់ដាជាតិជំពូកទី ១៩ ស្តីពីការគ្រប់គ្រងគុណភាពក្នុងសកម្មភាពមីន និងគោលការណ៍នៃការគ្រប់គ្រងហានិភ័យក្នុងសកម្មភាពមីន។ គោលការណ៍គ្រប់គ្រងគុណភាព ដែលមានការគ្រប់គ្រងដំណើរការកែលម្អ ការចូលរួមរបស់អ្នកពាក់ព័ន្ធ និងការសម្រេចចិត្តផ្អែកលើភស្តុតាងជាក់លាក់ គឺជាគោលការណ៍រួមដែលយកមកអនុវត្តក្នុងការគ្រប់គ្រងបរិស្ថានក្នុងសកម្មភាពមីន។ ការអនុវត្តវិធីសាស្ត្រកាត់បន្ថយផ្ទៃដី (LR) ដោយមិនប្រើប្រាស់ការបោសសម្អាតទាំងស្រុង គឺជាវិធីសាស្ត្រប្រកបដោយប្រសិទ្ធភាពបំផុតមួយ ដែលបន្ថយផលប៉ះពាល់នៃសកម្មភាពមីនដោយផ្ទាល់លើផ្ទៃដី។

## ១. វិសាលភាព

ស្តង់ដានេះ បញ្ជាក់ពីលក្ខខណ្ឌតម្រូវអប្បបរមាសម្រាប់ការគ្រប់គ្រងបរិស្ថាននៃប្រតិបត្តិការបោសសម្អាតមីនទាំងនៅលើដី និងក្រោមទឹក រួមមានការធ្វើផែនការ ការការពារ និងវិធានការកាត់បន្ថយផលប៉ះពាល់ដោយសកម្មភាពមីនមកលើបរិស្ថាន។ លក្ខខណ្ឌតម្រូវទាំងនេះត្រូវអនុវត្តដើម្បីធានាថា បរិស្ថានមិនត្រូវបានបំផ្លាញដោយសកម្មភាពមីន ហើយផ្ទៃដីត្រូវបានរក្សាស្រដៀងសភាពដើម ឬប្រសើរជាងមុន ក្រោយពេលប្រតិបត្តិការបោសសម្អាតមីន ព្រមទាំងអាចប្រើប្រាស់ដីដែលបោសសម្អាតរួចតាមការគ្រោងទុក។

## ២. ឯកសារយោង

បញ្ជីឯកសារយោងមាននៅក្នុងឧបសម្ព័ន្ធ "ក" ដែលជាផ្នែកមួយនៃស្តង់ដាការគ្រប់គ្រងបរិស្ថានក្នុងសកម្មភាពមីន។ ស្តង់ដានេះក៏អនុលោមតាមច្បាប់ និងបទបញ្ញត្តិនានាដែលពាក់ព័ន្ធនឹងការការពារបរិស្ថានរបស់ព្រះរាជាណាចក្រកម្ពុជា។

## ៣. វាក្យស័ព្ទ និងនិយមន័យ

វាក្យស័ព្ទ និងនិយមន័យទូទៅដែលបានប្រើប្រាស់នៅក្នុងស្តង់ដានេះមានដូចខាងក្រោម៖

**"បរិស្ថាន"** សំដៅលើអាកាស ខ្យល់ ទឹក ដី ធនធានធម្មជាតិ រុក្ខជាតិ សត្វ មនុស្ស និងទំនាក់ទំនងរវាងពួកគេនៅទីតាំងប្រតិបត្តិការរបស់ស្ថាប័នក្នុងវិស័យមីន។

**"ទិដ្ឋភាពបរិស្ថាន"** សំដៅលើសកម្មភាពនានា ផលិតផល ឬសេវាកម្ម របស់ស្ថាប័នក្នុងវិស័យមីន ដែលអាចបង្ក ឬបង្កផលប៉ះពាល់បរិស្ថាន។

**"ផលប៉ះពាល់បរិស្ថាន"** សំដៅលើការផ្លាស់ប្តូរសភាពបរិស្ថានទាំងវិជ្ជមាន និងអវិជ្ជមានដោយផ្នែក ឬទាំងស្រុងដែលជាលទ្ធផលនៃទិដ្ឋភាពបរិស្ថានរបស់ស្ថាប័នក្នុងវិស័យមីន។

**"ផលប៉ះពាល់អវិជ្ជមាន"** សំដៅលើឥទ្ធិពលដែលបង្កភាពអន្តរាយដល់បរិស្ថាន។ ការប្រៀបធៀបស្ថានភាពបច្ចុប្បន្ននៃការប្រើប្រាស់ដី និងស្ថានភាពនៃការប្រើប្រាស់ដីនៅពេលអនាគត គឺជាកត្តាសំខាន់ក្នុងការកំណត់ពីទំហំផលប៉ះពាល់អវិជ្ជមាន ដោយផ្អែកលើលក្ខខណ្ឌតម្រូវដែលមានចែងនៅក្នុងច្បាប់ជាតិ និងបទបញ្ញត្តិនានា។

**"ការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA)"** សំដៅលើដំណើរការនៃការកំណត់ ការប៉ាន់ស្មាន ការវាយតម្លៃ និងការកាត់បន្ថយផលប៉ះពាល់ដល់ជីវរូបសាស្ត្រ សង្គម និងផលប៉ះពាល់បរិស្ថានផ្សេងទៀតនៃសកម្មភាពក្នុង និងក្រោយពេលប្រតិបត្តិការ។

**"វិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន"** សំដៅលើវិធានការទាំងឡាយដែលបានអនុវត្តមុនពេល កំឡុងពេល និងក្រោយពេលប្រតិបត្តិការសកម្មភាពមីន ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានលើបរិស្ថាន។

**"ប្រព័ន្ធគ្រប់គ្រងបរិស្ថាន (EMS)"** សំដៅលើផ្នែកមួយនៃប្រព័ន្ធគ្រប់គ្រងសកម្មភាពមីន ដែលប្រើប្រាស់ដើម្បីគ្រប់គ្រងទិដ្ឋភាពបរិស្ថាន បំពេញកាតព្វកិច្ចអនុលោមតាមច្បាប់ និងដោះស្រាយហានិភ័យនានាដែលអាចកើតមាន។

**"ការហូរច្រោះ"** សំដៅលើដំណើរការសឹករិចរិលគុណភាពដី ការដាច់ចេញឬការហូរនាំដី និងសមាសធាតុ ផ្សេងៗទៀត និងលទ្ធភាពរក្សាសំណើម និងបាត់បង់ជីវជាតិដី ដោយសារអាកាសធាតុ ទឹកហូរច្រោះ ឬកម្លាំងខ្យល់ ។

## ៤. តម្រូវការទូទៅ

ប្រតិបត្តិការបោសសម្អាតមីន ត្រូវអនុវត្តឡើងដោយកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់បរិស្ថានមកត្រឹមកម្រិតអប្បបរមា និងមានសុវត្ថិភាពដល់បុគ្គលិកបោសសម្អាតមីន និងប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ រួមទាំង បុរស ស្ត្រី និងកុមារ។

ការធ្វើផែនការប្រតិបត្តិការសកម្មភាពមីន ត្រូវរួមបញ្ចូលការវាយតម្លៃលើទិដ្ឋភាពបរិស្ថានដែលពាក់ព័ន្ធ និងកំណត់វិធានការសមស្របមានប្រសិទ្ធភាព ដើម្បីកាត់បន្ថយផលប៉ះពាល់បរិស្ថាន។ ការវាយតម្លៃចាំបាច់ត្រូវគិតគូរពីការប្រែប្រួលអាកាសធាតុ (ភ្លៀងខ្លាំង ព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ រំកិលដី និងភាពរាំងស្ងួត។ល។) និងបញ្ហាបរិធានបន្សាំនៃការប្រែប្រួលអាកាសធាតុ។

ប្រតិបត្តិករបោសសម្អាតមីន ត្រូវចាត់វិធានការសមស្របដើម្បីធានាថា បរិស្ថាននៅការដ្ឋានបោសសម្អាតមីនរក្សាបាននូវសភាពដែលអាចប្រើប្រាស់ដីបោសសម្អាតរួច ស្របតាមគោលបំណងរំពឹងទុក។ ប្រតិបត្តិករបោសសម្អាតមីន គួរកំណត់វិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន តាមរយៈការពិចារណាអំពីតម្លៃដើម-ផលប្រយោជន៍នៃប្រតិបត្តិការ ដោយមានការព្រមព្រៀងជាមួយអាជ្ញាធរមីន។

ជាមួយគ្នានេះ ត្រូវយកចិត្តទុកដាក់ នៅពេលរៀបចំការដ្ឋានប្រតិបត្តិការដូចជា ការសាងសង់តំបន់រដ្ឋបាល ការដឹកជញ្ជូន ការហ្វឹកហ្វឺន ឬសកម្មភាពផ្សេងទៀត។ល។ ត្រូវធានាថា មិនបង្កផលប៉ះពាល់លើលក្ខខណ្ឌបរិស្ថាន សម្រាប់សហគមន៍អាស្រ័យផលចិញ្ចឹមជីវិត និងផ្គត់ផ្គង់សេដ្ឋកិច្ចនោះឡើយ។

## ៥. ការគ្រប់គ្រងបរិស្ថាន

អាជ្ញាធរមីន និងប្រតិបត្តិករបោសសម្អាតមីន ត្រូវមានប្រព័ន្ធគ្រប់គ្រងបរិស្ថាន។ ប្រតិបត្តិករបោសសម្អាតមីនទទួលខុសត្រូវក្នុងការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងដាក់ចេញវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន ដែលឆ្លុះបញ្ចាំងពីតម្រូវការថ្នាក់ជាតិ និងមូលដ្ឋានដោយមានការព្រមព្រៀងពីអាជ្ញាធរមីន។ ប្រតិបត្តិករមានការទទួលខុសត្រូវក្នុងការបំពេញតាមលក្ខណៈវិនិច្ឆ័យ និងវិធានការកាត់បន្ថយផលប៉ះពាល់នានា ដែលបានដាក់ចេញដោយអាជ្ញាធរមីន និងត្រូវមានប្រព័ន្ធគ្រប់គ្រងគុណភាពប្រកបដោយតម្លាភាព ដូចរៀបចំជាឯកសារពីនីតិវិធី និងមិនអនុលោមភាព(non-conformities)។

### ៥.១ គោលនយោបាយបរិស្ថាន

អាជ្ញាធរមីន និងប្រតិបត្តិករបោសសម្អាតមីនត្រូវបង្កើត ពិនិត្យឡើងវិញ និងអនុវត្តស្តង់ដាគ្រប់គ្រងបរិស្ថានដែល៖

- សមស្របនឹងសកម្មភាពរបស់ខ្លួន
- ដោយបញ្ជាក់ការប្តេជ្ញាចិត្តក្នុងការការពារបរិស្ថាន
- បង្ហាញការប្តេជ្ញាចិត្តអនុវត្តដោយអនុលោមតាមច្បាប់ និងបទបញ្ញត្តិនានា
- បង្ហាញការប្តេជ្ញាចិត្តក្នុងការកែលម្អជាបន្តបន្ទាប់លើការគ្រប់គ្រងបរិស្ថានក្នុងសកម្មភាពមីន
- ដោយផ្សព្វផ្សាយជូនភាគីពាក់ព័ន្ធ
- ត្រូវបានពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នភាពសមស្រប តាមការចាំបាច់។

ថ្នាក់ដឹកនាំជាន់ខ្ពស់របស់អាជ្ញាធរមីន និងប្រតិបត្តិករបោសសម្អាតមីនត្រូវធានាថា៖

- មានធនធានគ្រប់គ្រាន់សម្រាប់ការគ្រប់គ្រងបរិស្ថានប្រកបដោយប្រសិទ្ធភាពស្របតាមស្តង់ដានេះ
- មានបុគ្គលិកទទួលបានការបណ្តុះបណ្តាលគ្រប់គ្រាន់ និងមានការយល់ដឹងច្បាស់ពីតួនាទីរបស់ខ្លួនក្នុងការការពារបរិស្ថាន

- ដាក់បញ្ចូលការគ្រប់គ្រងបរិស្ថានទៅក្នុងបទដ្ឋានប្រតិបត្តិការ (SOP) និងឯកសារពាក់ព័ន្ធផ្សេងៗ
- ការរៀបចំឯកសារទាក់ទងនឹងការគ្រប់គ្រងបរិស្ថាន ត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ និងធ្វើឡើងដោយបើកចំហប្រកបដោយតម្លាភាព ព្រមទាំងមានជាភាសាផ្សេងបន្ថែមប្រសិនបើចាំបាច់ ដើម្បីជួយដល់ការយល់ដឹង
- ការអនុវត្តការគ្រប់គ្រងបរិស្ថានក្នុងសកម្មភាពមីនរបស់ប្រតិបត្តិករ ត្រូវបានត្រួតពិនិត្យ និងកែលម្អឱ្យប្រសើរឡើង។

## ៥.២ ស្វែងយល់អំពីបរិបទបរិស្ថាន

អាជ្ញាធរមីនត្រូវ៖

- កំណត់ និងវាយតម្លៃលើកាតព្វកិច្ចការពារបរិស្ថាននៃសកម្មភាពមីន ដូចមានចែងក្នុងច្បាប់ជាតិ និងអន្តរជាតិ (សូមមើលឧបសម្ព័ន្ធ "ក" )
- ស្វែងយល់ពីការវិភាគថ្លៃដើម-ផលប្រយោជន៍ នៃការការពារបរិស្ថាន
- កំណត់ និងពន្យល់ពីកាតព្វកិច្ចការពារបរិស្ថានក្នុងស្តង់ដាសកម្មភាពមីនកម្ពុជា និងឯកសារយោងពាក់ពន្ធ័នឹងការងារសកម្មភាពមីន
- កំណត់ និងសម្របសម្រួលជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការអនុវត្តការគ្រប់គ្រងបរិស្ថានក្នុងសកម្មភាពមីន
- សម្របសម្រួលជាមួយភាគីពាក់ព័ន្ធជាតិ និងអន្តរជាតិ ដើម្បីគាំទ្រនិងធ្វើឱ្យប្រសើរឡើងនូវវិធានការកាត់បន្ថយផលប៉ះពាល់ និងការការពារបរិស្ថាន ព្រមទាំងបញ្ចៀសនូវកិច្ចខិតខំប្រឹងប្រែងត្រួតគ្នា និងឆ្លើយតបទៅនឹងកង្វះខាតក្នុងការគ្រប់គ្រងបរិស្ថានក្នុងសកម្មភាពមីន។

ប្រតិបត្តិករបោសសម្អាតមីនត្រូវចាត់វិធានការសមស្របទាំងឡាយ ដើម្បីស្វែងយល់ពីតម្រូវការក្នុងការការពារបរិស្ថានក្នុងសកម្មភាពមីន និងការរំពឹងទុករបស់ភាគីពាក់ព័ន្ធ រួមទាំងសមាជិកសហគមន៍ (បុរស និងស្ត្រី) ។

ការយល់ដឹងពីបរិស្ថាន តម្រូវការ និងការរំពឹងទុករបស់ភាគីពាក់ព័ន្ធក្នុងសកម្មភាពមីន ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងការធ្វើផែនការ និងការដាក់ចេញនូវវិធានការកាត់បន្ថយផលប៉ះពាល់ និងការការពារបរិស្ថាន។

## ៥.៣ កំណត់ និងវាយតម្លៃទិដ្ឋភាពបរិស្ថាន

សម្រាប់លក្ខខណ្ឌតម្រូវអប្បបរមា ប្រតិបត្តិករបោសសម្អាតមីនត្រូវកំណត់ វាយតម្លៃ និងចងក្រងឯកសារស្តីពីទិដ្ឋភាពបរិស្ថាន ធាតុចូល ផលិតផល និងសេវាកម្មដែលកើតចេញពីសកម្មភាពមីន រួមមាន៖

- ការបំភាយឧស្ម័នក្នុងខ្យល់
- ការបញ្ចេញទៅក្នុងទឹក
- ការបញ្ចេញទៅក្នុងដី
- ការប្រើប្រាស់វត្ថុធាតុដើម និងធនធានធម្មជាតិ
- ការប្រើប្រាស់ថាមពល
- ការបំភាយថាមពល
- ការបង្កើតកាកសំណល់។

ប្រតិបត្តិករបោសសម្អាតមីនត្រូវកំណត់ទិដ្ឋភាពទាំងឡាយ ដែលអាចបង្កផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន ដូចខាងក្រោម៖

- ការហូរច្រោះ និងសំណឹកដី
- ការបំពុលខ្យល់ ទឹក និងដី
- ការបន្ទុចបង្អាក់ ការរំខាន ឬការបង្កអន្តរាយដល់សហគមន៍ ហេដ្ឋារចនាសម្ព័ន្ធ ព្រៃឈើ និងសត្វព្រៃ
- សំរាម កម្ទេចកម្ទី សំណល់ និងការរិចរិលបរិស្ថាន
- ការខូចខាតតំបន់បេតិកភណ្ឌ និងវត្ថុបុរាណផ្សេងៗ។

នៅពេលធ្វើការវាយតម្លៃពីសារៈសំខាន់នៃបរិស្ថាន ប្រតិបត្តិករបោសសម្អាតមីនគួរគិតគូរពីលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- ប្រភេទសកម្មភាពមីន
- ទំហំប្រតិបត្តិការសកម្មភាពមីន
- ចំនួនកិច្ចប្រតិបត្តិការសកម្មភាពមីន
- រយៈពេលប្រតិបត្តិការសកម្មភាពមីន
- វេទយិតភាពបរិស្ថាននៅតាមការដ្ឋាន
- ភាពធ្ងន់ធ្ងរនៃផលប៉ះពាល់
- តម្រូវការផ្នែកច្បាប់ ឬបទដ្ឋានពាក់ព័ន្ធ
- ការរំពឹងទុករបស់អ្នកពាក់ព័ន្ធផ្នែកបរិស្ថាន
- ផលប៉ះពាល់អវិជ្ជមានរួមគ្នាដែលអាចកើតមានលើបរិស្ថាន
- ទំនួលខុសត្រូវផ្នែកច្បាប់ ដែលអាចកើតមានឡើងពាក់ព័ន្ធទិដ្ឋភាពបរិស្ថាន។

ត្រូវដាក់បញ្ចូលរាល់ទិដ្ឋភាពបរិស្ថានទៅក្នុងឯកសារផែនការ បទដ្ឋានប្រតិបត្តិការ និងក្នុងកំណត់ត្រាផ្សេងៗ។

ប្រតិបត្តិករបោសសម្អាតមីនគួរវាយតម្លៃ និងប្រើប្រាស់ឱកាសដើម្បីការពារបរិស្ថានដោយប្រយោលតាមរយៈការធ្វើលទ្ធកម្មធនធាន ការបែងចែកការងារ ការដឹកជញ្ជូន ការស្តុកទុក និងការកម្ទេចចោលកាកសំណល់។

## ៥.៤ កំណត់វិធានការការពារ និងកាត់បន្ថយផលប៉ះពាល់បរិស្ថាន

ប្រតិបត្តិករបោសសម្អាតមីនត្រូវកំណត់វិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថានសមស្រប និងមានប្រសិទ្ធភាពដោយគិតគូរពីហានិភ័យទាំងឡាយដែលអាចកើតមាន។

ចងក្រងឯកសារអំពីវិធានការការពារ កាត់បន្ថយផលប៉ះពាល់បរិស្ថាន និងដាក់បញ្ចូលវិធានការទាំងនោះទៅក្នុងលិខិតបញ្ជាភារកិច្ច ផែនការប្រតិបត្តិការ បទដ្ឋានប្រតិបត្តិការ និងឯកសារពាក់ព័ន្ធផ្សេងទៀត។

វិធានការការពារ និងកាត់បន្ថយផលប៉ះពាល់បរិស្ថាន ត្រូវមានបញ្ចូលផែនការឆ្លើយតបជាបន្ទាន់ចំពោះឧបទ្ទវហេតុបរិស្ថាន និងផែនការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

## ៥.៥ ការវាយតម្លៃផលប៉ះពាល់បរិស្ថាន

ក្នុងកាលៈទេសៈខ្លះ ការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA) សមស្រប ឬតម្រូវឱ្យមានជាចាំបាច់ (សូមមើលឧបសម្ព័ន្ធ "ក" និង "គ")។ ការវាយតម្លៃផលប៉ះពាល់បរិស្ថាន គួរធ្វើនៅពេល៖

- ប្រតិបត្តិការបោសសម្អាតមីនអាចនឹងកើតឡើងនៅក្នុង ឬក្បែរតំបន់ដែលកំណត់ថា ជាតំបន់ការពារបរិស្ថាន ឬតំបន់ដែលគេស្គាល់ថាអាចនឹងមានវេទយេតភាពបរិស្ថាន
- មានលក្ខខណ្ឌតម្រូវជាកាតព្វកិច្ចផ្លូវច្បាប់ ឬកិច្ចសន្យា
- អាជ្ញាធរមីន និងប្រតិបត្តិករបោសសម្អាតមីនកំណត់ថា ការវាយតម្លៃផលប៉ះពាល់បរិស្ថានមានភាពចាំបាច់
- នៅពេលមានភាពមិនច្បាស់លាស់អំពីទំហំ ឬសារៈសំខាន់នៃផលប៉ះពាល់បរិស្ថាន។

## ៥.៦ ការរៀបចំ និងបែងចែកភារកិច្ចនៃប្រតិបត្តិការបោសសម្អាតមីន

នៅពេលរៀបចំផែនការប្រតិបត្តិការសកម្មភាពមីន ប្រតិបត្តិករបោសសម្អាតមីនត្រូវពិចារណាលើគោលការណ៍ណែនាំក្នុងឧបសម្ព័ន្ធ "គ" នៃស្តង់ដានេះ។

ការរៀបចំផែនការប្រតិបត្តិការបោសសម្អាតមីនត្រូវ៖

- សមស្របទៅនឹងបរិបទនៃបរិស្ថាន
- ពិចារណាលើកាតព្វកិច្ចផ្លូវច្បាប់ និងអនុលោមភាពទៅនឹងកាតព្វកិច្ចផ្សេងៗ
- ពិចារណាលើគោលបំណងប្រើប្រាស់ដីដែលបានបោសសម្អាតមីនរួច
- ស្វែងយល់ពីតម្លៃដើម-ផលប្រយោជន៍នៃវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន
- ត្រូវមានបញ្ចូលវិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាននានាដូចជា ការឆ្លើយតបជាបន្ទាន់ក្នុងព្រឹត្តិការណ៍ប្រែប្រួលអាកាសធាតុធ្ងន់ធ្ងរ ទឹកជំនន់ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ (ភាពរាំងស្ងួត ឬអគ្គីភ័យ។ល។)
- ត្រូវអនុលោមតាមស្តង់ដាស្តីពីការគ្រប់គ្រងបរិស្ថានក្នុងសកម្មភាពមីន។

## ៥.៧ ការអនុវត្តកិច្ចប្រតិបត្តិការ

អាជ្ញាធរមីន និងប្រតិបត្តិករបោសសម្អាតមីនត្រូវគោរពតាមលក្ខខណ្ឌតម្រូវនានា ដូចមានចែងនៅក្នុងស្តង់ដានេះ និងគោលការណ៍ណែនាំផ្សេងៗដែលពាក់ព័ន្ធនឹងកិច្ចប្រតិបត្តិការបោសសម្អាតមីន និងផ្អែកតាមបទដ្ឋានប្រតិបត្តិការរបស់ខ្លួន។ នៅពេលអនុវត្តកិច្ចប្រតិបត្តិការសកម្មភាពមីន ប្រតិបត្តិករត្រូវពិចារណាលើគោលការណ៍ណែនាំក្នុងឧបសម្ព័ន្ធ "គ" នៃស្តង់ដានេះ។

អាជ្ញាធរមីន និងប្រតិបត្តិករបោសសម្អាតមីន ត្រូវចាត់តាំងអ្នកទទួលខុសត្រូវក្នុងការការពារបរិស្ថាននៅកន្លែងបោសសម្អាតមីន និងធានាអនុលោមភាពតាមលក្ខខណ្ឌតម្រូវក្នុងការការពារបរិស្ថាន តាមរយៈការគ្រប់គ្រងគម្រោង ការអនុវត្តកិច្ចសន្យា និងដំណើរការប្រតិបត្តិការផ្សេងៗ។

ប្រតិបត្តិករបោសសម្អាតមីនទាំងអស់ត្រូវលើកកម្ពស់ចំណេះដឹង និងសមត្ថភាពការពារបរិស្ថានដល់បុគ្គលិក តាមរយៈការអប់រំ និងបណ្តុះបណ្តាល។ ជាមួយគ្នានេះ គួរបញ្ជ្រាបការការពារ និងការថែរក្សាបរិស្ថានក្រោយការបោសសម្អាតមីន ការចូលរួមផ្សេងៗរបស់សហគមន៍ ទៅក្នុងការអប់រំអំពីគ្រោះថ្នាក់ដោយសារយុទ្ធភណ្ឌគ្រឿងផ្ទុះ (EORE) ។ ប្រតិបត្តិករគួរផ្តល់ការបណ្តុះបណ្តាលអំពីការឆ្លើយតប និងត្រៀមបម្រុងបន្ទាន់ក្នុងព្រឹត្តិការណ៍ឧបទ្ទវហេតុបរិស្ថានធ្ងន់ធ្ងរ។

វិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន ត្រូវបង្កើតឡើងដើម្បីទប់ស្កាត់ផលប៉ះពាល់បរិស្ថានជាអវិជ្ជមាន ការពារការបំពុល និងបំផ្លាញបរិស្ថាន (ដី ខ្យល់ និងទឹក)។ បន្ថែមពីលើនេះ កិច្ចខិតខំប្រឹងប្រែងត្រូវធ្វើឡើងដើម្បីការពារផលប៉ះពាល់ជាអវិជ្ជមានដល់រុក្ខជាតិ និងសត្វព្រៃក្នុងអំឡុងពេលប្រតិបត្តិការបោសសម្អាតមីន។

មិនត្រូវបង្ហូរកាកសំណល់របស់មនុស្សចូលក្នុងទឹក ឬលើផ្ទៃដីឡើយ។ ប្រតិបត្តិករបោសសម្អាតមីន ត្រូវកាត់បន្ថយផលប៉ះពាល់លើបរិស្ថានដែលបណ្តាលមកពីកិច្ចប្រតិបត្តិការរបស់ខ្លួន និងត្រូវចាត់វិធានការសមស្របនានា យកកាកសំណល់ចេញពីកន្លែងធ្វើការនៅពេលបញ្ចប់ប្រតិបត្តិការ និងមុនពេលធ្វើការប្រគល់ដីដែលបានបោសសម្អាតរួច។ ត្រូវប្រមូល និងចោលសំរាមនៅកន្លែងដែលបានកំណត់។ ត្រូវសម្អាតសំរាមដែលកំពប់ក្នុងអំឡុងពេលប្រមូលចេញ។ មិនត្រូវបង្ហូរទឹកស្អុយទៅលើដី ឬចូលប្រភពទឹក។

ការប្រើប្រាស់ ការជួសជុល និងការថែទាំឧបករណ៍បោសសម្អាតមីន ត្រូវធ្វើឡើងដោយកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងអនុលោមតាមលក្ខខណ្ឌតម្រូវនៃការវាយតម្លៃផលប៉ះពាល់បរិស្ថាន។

ប្រតិបត្តិការបោសសម្អាតមីន អាចធ្វើឡើងនៅក្នុងតំបន់វប្បធម៌ប្រវត្តិសាស្ត្រ ប៉ុន្តែអាជ្ញាធរមីន និងប្រតិបត្តិករបោសសម្អាតមីនត្រូវចាត់វិធានការការពារ មិនឱ្យមានការខូចខាតទីតាំងទាំងនោះ។

រាល់វិធានការកាត់បន្ថយផលប៉ះពាល់បរិស្ថាន ដែលមានចែងលម្អិតក្នុងស្តង់ដាជាតិសកម្មភាពមីន បទដ្ឋានប្រតិបត្តិការ ការបញ្ជាភារកិច្ច ឬក្នុងឯកសារផ្សេងទៀតត្រូវអនុវត្តឱ្យបានពេញលេញ និងមានប្រសិទ្ធភាពអំឡុងពេលប្រតិបត្តិការ មុនពេលផ្ទេរ-ប្រគល់ផ្ទៃដី និងមុនចាកចេញពីការដ្ឋានរបស់ប្រតិបត្តិករ។

## ៥.៨ ការត្រួតពិនិត្យទិដ្ឋភាពបរិស្ថាន

អាជ្ញាធរមីន និងប្រតិបត្តិករបោសសម្អាតមីន ត្រូវអនុវត្តប្រព័ន្ធត្រួតពិនិត្យស្របតាមស្តង់ដាជំពូកទី៣ និងធានាថាតម្រូវការបរិស្ថានត្រូវបានដាក់បញ្ចូល។

ការឆ្លើយតបទៅនឹងភាពមិនអនុលោមដែលបង្កផលប៉ះពាល់លើបរិស្ថាន ត្រូវអនុវត្តទៅតាមស្តង់ដាជំពូកទី១៩ និងជំពូកទី៣។ ឧបទ្ទវហេតុ ឬគ្រោះថ្នាក់លើបរិស្ថានគួរតែត្រូវបានចាត់ទុកជាភាពមិនអនុលោម បន្ថែមលើនេះការស៊ើបអង្កេតនឹងត្រូវធ្វើឡើងដោយផ្អែកតាមស្តង់ដាជំពូកទី៥។

ការវាយតម្លៃផលប៉ះពាល់ពីការប្រើប្រាស់ផ្ទៃដីដែលបានបោសសម្អាតរួច គួរបញ្ចូលការវាយតម្លៃផលប៉ះពាល់ទិដ្ឋភាពបរិស្ថាន និងវិធានការនានាក្នុងការកាត់បន្ថយផលប៉ះពាល់បរិស្ថាន។ ការវាយតម្លៃនេះ គួរគិតគូរទៅលើលទ្ធផលនៃការប្រើប្រាស់ដីដែលបានបោសសម្អាតមីនរួច ឧបទ្ទវហេតុបរិស្ថាន និងជម្លោះដីធ្លីដែលអាចកើតមាន។

## ៥.៩ ការពិនិត្យ និងការកែលម្អ

យោងស្តង់ដាជំពូកទី១៩ ការពិនិត្យឡើងវិញគួរបញ្ចូលទិដ្ឋភាពបរិស្ថាន និងត្រូវធ្វើឡើងដោយមានការចូលរួមពីថ្នាក់ដឹកនាំជាន់ខ្ពស់អាជ្ញាធរមីន និងប្រតិបត្តិករបោសសម្អាតមីន ដើម្បីធានាប្រសិទ្ធភាព ភាពសមស្រប និងអនុលោមតាមស្តង់ដាបរិស្ថានរបស់ប្រតិបត្តិករនីមួយៗ។

ការពិនិត្យឡើងវិញ គួរត្រូវបានធ្វើឡើងស្របតាមតម្រូវការ កាលៈទេសៈ និងគួរពិចារណាលើចំណុចដូចខាងក្រោម៖

- សកម្មភាពដែលបានធ្វើឆ្លើយតបនឹងការត្រួតពិនិត្យពីលើកមុន
- ការផ្លាស់ប្តូរបរិបទបរិស្ថាននៃសកម្មភាពមីន
- ការអនុវត្តការគ្រប់គ្រងបរិស្ថានរបស់ប្រតិបត្តិករបោសសម្អាតមីន ដែលរួមមាន៖
  - ការឆ្លើយតបចំពោះសេចក្តីត្រូវការ និងការរំពឹងទុករបស់អ្នកពាក់ព័ន្ធស្តីពីការការពារបរិស្ថាន
  - ការអនុលោមតាមស្តង់ដាបរិស្ថាន
  - ភាពមិនអនុលោម និងសកម្មភាពកែតម្រូវ
  - ត្រួតពិនិត្យ វាស់វែង សវនកម្ម និងការវាយតម្លៃលទ្ធផលនៃការអនុវត្តការគ្រប់គ្រងបរិស្ថាន។

- ឱកាសសម្រាប់ការកែលម្អការគ្រប់គ្រងបរិស្ថាន។

ការពិនិត្យឡើងវិញគួរមានការសម្រេចចិត្ត និងវិធានការដែលទាក់ទងនឹងៈ

- ការកែលម្អការគ្រប់គ្រងបរិស្ថាន
- ការផ្លាស់ប្តូរការគ្រប់គ្រងបរិស្ថាន
- សកម្មភាពដែលត្រូវធ្វើ អ្នកទទួលខុសត្រូវ កាលវិភាគ និងការផ្ទៀងផ្ទាត់ការអនុវត្តប្រកបដោយប្រសិទ្ធភាព។

លទ្ធផលនៃការពិនិត្យឡើងវិញ ត្រូវផ្សព្វផ្សាយដល់បុគ្គលិក អ្នកគ្រប់គ្រង និងអ្នកពាក់ព័ន្ធនានា។ ស្តង់ដានេះត្រូវពិនិត្យឡើងវិញតាមការចាំបាច់។

## ៦. ទំនួលខុសត្រូវ និងភារកិច្ច

### ៦.១ ការទទួលខុសត្រូវរបស់អាជ្ញាធរមីន

- ចងក្រងឯកសារនៃការគ្រប់គ្រងបរិស្ថាន ដូចមាននៅក្នុងស្តង់ដាជាតិសកម្មភាពកំចាត់មីនកម្ពុជា កិច្ចសន្យា គោលការណ៍ណែនាំ និងឯកសារផ្សព្វផ្សាយផ្សេងទៀត
- ត្រួតពិនិត្យអនុលោមភាពនៃការអនុវត្តការគ្រប់គ្រងបរិស្ថាន
- ធានានូវការអនុវត្ត EIA ប្រសិនបើចាំបាច់
- ធានាថា ការការពារបរិស្ថានត្រូវបានយកមកពិចារណាក្នុងអំឡុងពេលរៀបចំផែនការប្រតិបត្តិការបោសសម្អាតមីន
- រក្សាកំណត់ត្រានៃឧបទ្ទវហេតុបរិស្ថានដែលបានរាយការណ៍
- ក្នុងករណីចាំបាច់ធ្វើការស៊ើបអង្កេតលើឧបទ្ទវហេតុបរិស្ថាន
- ផ្សព្វផ្សាយព័ត៌មានអំពីទិដ្ឋភាពបរិស្ថានសំខាន់ៗនៃសកម្មភាពមីន រួមទាំងអនុសាសន៍សម្រាប់ឧត្តមានុវត្ត និងព័ត៌មានលម្អិតនៃឧបទ្ទវហេតុបរិស្ថានដល់ប្រតិបត្តិករបោសសម្អាតមីន និងភាគីពាក់ព័ន្ធដទៃទៀត
- សម្របសម្រួលការការពារបរិស្ថានជាមួយភាគីពាក់ព័ន្ធកម្រិតជាតិ និងអន្តរជាតិ។

### ៦.២ ការទទួលខុសត្រូវរបស់ប្រតិបត្តិករបោសសម្អាតមីន

ប្រតិបត្តិករបោសសម្អាតមីនត្រូវៈ

- បង្កើត ថែរក្សា និងពន្យល់នីតិវិធីប្រតិបត្តិការ ស្តីពីការការពារបរិស្ថានដែលស្របនឹងស្តង់ដាជាតិសកម្មភាពកំចាត់មីនកម្ពុជា ស្តីពីការគ្រប់គ្រងបរិស្ថានក្នុងសកម្មភាពមីន
- ចងក្រងឯកសារនៃការគ្រប់គ្រងបរិស្ថានក្នុងនីតិវិធីប្រតិបត្តិការ ឬឯកសារពាក់ព័ន្ធផ្សេងទៀត និងធានាថាបុគ្គលិកទាំងអស់ត្រូវបានបណ្តុះបណ្តាល និងយល់ដឹងអំពីតម្រូវការពាក់ព័ន្ធលើបរិស្ថាន
- ធានាថាការការពារបរិស្ថានគឺជាផ្នែកមួយក្នុងការរៀបចំផែនការ និងការអនុវត្តកិច្ចប្រតិបត្តិការបោសសម្អាតមីន
- រក្សាកំណត់ត្រានៃការមិនអនុលោមបរិស្ថាន ឧបទ្ទវហេតុបរិស្ថាន និងគ្រប់គ្រងការមិនផ្អែកតាមស្តង់ដាជាតិជំពូកទី៣ និងជំពូកទី១៩
- រាយការណ៍អំពីឧបទ្ទវហេតុបរិស្ថានសំខាន់ៗជូនដល់អាជ្ញាធរមីន។

### ៦.៣ ការទទួលខុសត្រូវរបស់ម្ចាស់ជំនួយ និងភាគីពាក់ព័ន្ធផ្សេងទៀត

- ម្ចាស់ជំនួយត្រូវស្វែងយល់ពីទិដ្ឋភាពបរិស្ថាននៃសកម្មភាពមីន និងផលប៉ះពាល់ដែលអាចកើតឡើង
- ម្ចាស់ជំនួយគួរតែលើកកម្ពស់ការយល់ដឹង និងការស្វែងយល់អំពីតួនាទីនៃការការពារបរិស្ថាន និងវិធានការកាត់បន្ថយផលប៉ះពាល់ ក្នុងការចូលរួមកែលម្អស្ថានភាពសេដ្ឋកិច្ច និងសង្គមលើកម្រិតមូលដ្ឋាន និងថ្នាក់ជាតិ
- ម្ចាស់ជំនួយគួរតែបញ្ជាក់លើភាពចាំបាច់នៃតម្រូវការក្នុងការការពារបរិស្ថានដល់អាជ្ញាធរមីន និងប្រតិបត្តិករបោសសម្អាតមីន
- អង្គការដែលសកម្មក្នុងការការពារបរិស្ថាន អាចចូលរួមធនធានដើម្បីលើកកម្ពស់ការយល់ដឹង និងការអនុវត្តវិធានការណ៍ការពារ និងកាត់បន្ថយផលប៉ះពាល់លើបរិស្ថាន
- ភាគីពាក់ព័ន្ធគួរតែយល់ដឹងអំពីបញ្ហាប្រឈមក្នុងការការពារបរិស្ថាន ក្នុងកិច្ចប្រតិបត្តិការបោសសម្អាតមីននៅពេលបង្កើតឧបករណ៍ ឬការកំណត់លក្ខខណ្ឌតម្រូវ។

ថ្ងៃ ចន្ទ ១៤កើត ខែ ជេស្ឋ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០២២

**អគ្គលេខាធិការ**

**ប្រាំ សុភមង្គល**

**ឧបសម្ព័ន្ធ ក: ឯកសារយោង**

ផ្នែកខ្លះៗនៃបទដ្ឋានខាងក្រោម ត្រូវបានដកស្រង់យកមកប្រើនៅក្នុងស្តង់ដានេះ៖

- ស្តង់ដាជំពូក ២ "ការផ្តល់ប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណប្រតិបត្តិការជូនប្រតិបត្តិករ"
- ស្តង់ដាជំពូក ៣ "ការត្រួតពិនិត្យប្រតិបត្តិករបោសសម្អាតមីន"
- ស្តង់ដាជំពូក ៤ " ការរក្សាទុក ការដឹកជញ្ជូន និងការប្រើប្រាស់រំសេវផ្ទុះ"
- ស្តង់ដាជំពូក ៥ "សេចក្តីរាយការណ៍ និងការអង្កេតឧបទ្ទវហេតុគ្រោះថ្នាក់ក្នុងពេលដោះមីន"
- ស្តង់ដាជំពូក ៨ "កិច្ចប្រតិបត្តិការកម្ទេចគ្រឿងផ្ទុះ"
- ស្តង់ដាជំពូក ១៥ "ការកាត់បន្ថយផ្ទៃដីចម្ការមីន"
- ស្តង់ដាជំពូក ១៦ "ការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម"
- ស្តងដាជំពូក ១៩ "ការគ្រប់គ្រងគុណភាពក្នុងសកម្មភាពមីន"
- ផែនការយុទ្ធសាស្ត្រជាតិសកម្មភាពមីន ២០១៨-២០២៥។

ប្រតិបត្តិករ គួរតែមានច្បាប់ចម្លងមុនពេលចាប់ផ្តើមកម្មវិធីបោសសម្អាតមីន។

**ឧបសម្ព័ន្ធ ខ: គោលការណ៍ណែនាំស្តីពីវិធានការការពារ និងកាត់បន្ថយផលប៉ះពាល់បរិស្ថាន**

**ខ.១. សេចក្តីផ្តើម**

អនុសាសន៍ទូទៅមួយចំនួនពីមេរៀនដែលបានទទួល ផ្តល់នូវការណែនាំបន្ថែមសម្រាប់ការពារបរិស្ថាន និងវិធានការកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន ទាក់ទងនឹងសកម្មភាពមីន។ ឧបសម្ព័ន្ធនេះ ផ្តល់នូវការណែនាំបន្ថែមលើលក្ខណៈខុសៗគ្នានៃផលប៉ះពាល់ និងវិធានការកាត់បន្ថយនានាដែលអាចត្រូវបានអនុវត្តដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន។ គោលការណ៍នេះ ត្រូវបានផ្តល់ជូនសម្រាប់គោលបំណងណែនាំ ហើយមិនមានលក្ខណៈតឹងរឹង ឬគ្រប់ជ្រុងជ្រោយនោះទេ។

វិធីសាស្ត្រចម្បងមួយក្នុងការកាត់បន្ថយផលប៉ះពាល់ដោយផ្ទាល់ទៅលើផ្ទៃដី និងរុក្ខជាតិ គឺតាមរយៈការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលការណ៍កាត់បន្ថយផ្ទៃដី ដូចមានចែងលម្អិតនៅក្នុងស្តង់ដាជំពូកទី ១៥ ។

**ខ.២. ការហូរច្រោះ និងសំណឹកដី**

សំណឹកដីបណ្តាលមកពីដំណើរការធម្មជាតិដែលធ្វើឱ្យចលនាផ្លាស់ប្តូរទីតាំង ឬល្បាយដីហូរច្រោះ។ សំណឹកអាចកើតឡើងដោយសកម្មភាពរបស់មនុស្ស ដែលធ្វើឱ្យមានការរំខានដល់ផ្ទៃដីខាងលើ។ ល្បាយដីនៅផ្ទៃខាងលើអាចហូរច្រោះ និងសឹករិចរិល ដោយសារ ខ្យល់ ទឹករលក ឬលំហូរតាមជម្រាល។

សំណឹកដីកើតឡើងនៅពេលដែលការផ្លាស់ប្តូរជម្រៅដី ឬលក្ខណៈរូបវន្ត ឬសមាសធាតុធ្វើឱ្យខូចគុណភាពដី។ សំណឹកដីរួមមាន ការបាត់បង់ដីស្រទាប់ខាងលើដែលសំបូរទៅដោយសារធាតុចិញ្ចឹម/ជីវជាតិតាមរយៈការសឹករិចរិល និងការបាត់បង់សារធាតុសរីរាង្គ ជាតិប្រៃ ជាតិអាស៊ីត និងការបាត់បង់ស្ថេរភាពនៃសណ្ឋានដី ។

វិធានការបន្ថយផលប៉ះពាល់ ត្រូវធានាថាប្រតិបត្តិការស្រាវជ្រាវ និងបោសសម្អាតមីន មិនបង្កឱ្យមានការហូរច្រោះ ឬសំណឹកដីបន្ថែម។ ប្រសិនបើតំបន់ណាត្រូវបានរងផលប៉ះពាល់នៃការហូរច្រោះរួចហើយ គួរចាត់វិធានការកាត់បន្ថយផលប៉ះពាល់ទាំងនេះ។ វិធានការទាំងនេះរួមមាន៖

- កម្រិត ឬបង្រួមតំបន់ដែលមានការស្រាវជ្រាវបច្ចេកទេស ដោយប្រើវិធីសាស្ត្របោសសម្អាតដោយដៃ ឬគ្រឿងចក្រតាមរយៈប្រតិបត្តិការស្រាវជ្រាវតាមគោលដៅ និងការបោសសម្អាត

- ដាំឡើងវិញ (ឧទាហរណ៍៖ ស្មៅ ដើមឈើ ចាក់ដីបំពេញរណ្តៅ) បន្ទាប់ពីបញ្ចប់ប្រតិបត្តិការសកម្មភាពមីន ឬអាចជ្រើសពេលវេលាណាដែលសមស្រប
- ការពង្រាបដីឱ្យស្មើជាផ្នែកមួយនៃដំណើរការផ្ទេរប្រគល់ដី បន្ទាប់ពីពិគ្រោះយោបល់ជាមួយអ្នកទទួលផលក្នុងតំបន់
- ការរៀបចំប្រព័ន្ធលំហូរទឹក
- រៀបចំកាលវិភាគប្រតិបត្តិការស្រាវជ្រាវបច្ចេកទេស និងបោសសម្អាតមីន ដែលអាចឱ្យការដាំដុះនៅទីតាំងនោះ ធ្វើទៅបានយ៉ាងឆាប់តាមតែអាចទៅរួច បន្ទាប់ពីប្រតិបត្តិការត្រូវបានបញ្ចប់
- កំណត់ពេលបោសសម្អាតមីនក្នុងកំឡុងពេលដែលដី និងព្រៃឈើមិនសូវងាយរងគ្រោះ
- ដានដីលើផ្លូវដែលមានជម្រៅជ្រៅ ឬរណ្តៅបំផ្ទុះ គួរតែត្រូវបានបំពេញឡើងវិញ ដើម្បីកាត់បន្ថយការហូរច្រោះ
- បំពេញដីដែលបានឈូសឆាយត្រឡប់ចូលក្នុងកន្លែងដែលរងផលប៉ះពាល់ (ឧទាហរណ៍៖ ដីដែលត្រូវបានរែង ឬឈូសឆាយយកចេញដោយគ្រឿងចក្រ)
- ត្រូវរក្សាទុកដីដែលបានយកចេញនៅក្នុងតំបន់ដែលមិនមានសំណឹកដី ក្នុងពេលកំពុងប្រតិបត្តិការ
- មិនត្រូវកាប់បំបែកស្រទាប់ដីខាងលើជាលក្ខណៈទ្រង់ទ្រាយធំ
- សហគមន៍មូលដ្ឋានត្រូវចូលរួមនៅក្នុងដំណើរការនៃការអនុវត្តវិធានការកាត់បន្ថយផលប៉ះពាល់
- ការស្រាវជ្រាវបច្ចេកទេស និងការបោសសម្អាតគួរធ្វើឡើងនៅពេលដែលអាកាសធាតុមិនបង្កដល់ការហូរច្រោះ
- មិនត្រូវឱ្យមានរំខានចរន្តទឹក ឬបង្វែរលំហូរទឹកធម្មជាតិជាអចិន្ត្រៃយ៍ ដោយប្រតិបត្តិការបោសសម្អាតមីនឡើយ
- ប្រសិនបើចាំបាច់ត្រូវបង្វែរលំហូរទឹក ឬធ្វើទំនប់ទឹក ត្រូវពិភាក្សា និងសុំការយល់ព្រមពីម្ចាស់ដី ឬសហគមន៍មូលដ្ឋាន មុនពេលចាប់ផ្តើមការងារ
- ទំនាក់ទំនងនិងសម្របសម្រួលជាមួយសហគមន៍ជាប្រចាំ អំពីកិច្ចប្រតិបត្តិការគ្រឿងចក្រ រួមទាំងការផ្តល់យោបល់ដល់ម្ចាស់អចលនទ្រព្យ អាជ្ញាធរមូលដ្ឋាន និងសហគមន៍ពីការខូចខាតដែលអាចកើតមានដល់បរិស្ថាន។ បើចាំបាច់ គួរផ្តល់យោបល់/ដំបូន្មានក្នុងការកាត់បន្ថយការខូចខាតអប្បបរមាឱ្យម្ចាស់អចលនទ្រព្យ/ អ្នកត្រួតពិនិត្យដីដែលនៅជាប់នឹងការដ្ឋានសកម្មភាពមីន។

## ៥.៣ . ការបំពុលខ្យល់ ទឹក និងដីដោយសារជាតិពុល និងសារធាតុគីមីគ្រោះថ្នាក់

ត្រូវពិនិត្យតំបន់ជុំវិញ (រួមមានរុក្ខជាតិ និងសត្វព្រៃ) ដើម្បីបញ្ជាក់ថាតើនៅមានអំបែងគ្រាប់ សារធាតុពុល ឬសារធាតុគ្រោះថ្នាក់ ប្រសិនបើមានត្រូវចាត់វិធានការលុបបំបាត់ ឬកាត់បន្ថយសំណល់ក្នុងកម្រិតអប្បបរមា ដែលអាចរំខានដល់មនុស្ស សត្វព្រៃ និងព្រៃឈើ។

សមាសធាតុគីមីផ្សេងៗមកពីមីន គ្រាប់បែកចង្កោម សំណល់ជាតិផ្ទុះពីសង្គ្រាម និងគ្រឿងផ្ទុះកែច្នៃ អាចលាយចូលក្នុងខ្សែទឹក និងមានប្រតិកម្មជាមួយរ៉ែដែលមានស្រាប់នៅក្នុងដី បង្កើតបានជាសារធាតុគីមីថ្មី។ សំបកគ្រាប់មីន រំសេវ សារធាតុពុលដែលលេចចេញពីគ្រាប់មីន (ជាពិសេសគ្រឿងផ្ទុះកែច្នៃ) នៅលើដី ឬនៅក្រោមដី អាចប៉ះពាល់ដោយផ្ទាល់លើគុណភាពដី តាមរយៈការផ្ទុះ ឬការលេចធ្លាយនៃសារធាតុពុលចេញពីសំបកគ្រាប់ ដែលបណ្តាលមកពីភាពច្រេះ ឬភាពពុកផុយ។

ផលវិបាកដែលបង្កដោយភាពច្រេះរបស់អំបែងគ្រាប់អាចបញ្ចេញសាធាតុលោហៈនានាដូចជា ធាតុ

ដែក ម៉ង់ហ្គាណែស ក្រូមីញ៉ូម ស័ង្កសី និងទង់ដែងជាដើម។ បរិមាណនៃសារធាតុពុលគ្រោះថ្នាក់ អាចលេចចេញក្រោយការប្រើប្រាស់អាវុធដែលមានសារធាតុផ្ទុះខ្លាំង ។ នៅក្នុងតំបន់កសិកម្ម សារធាតុពុលអាចជ្រាបចូលទៅក្នុងខ្សែសង្វាក់ផលិតកម្មម្ហូបអាហារ។ នៅពេលសារធាតុពុលជ្រាបចូលក្នុងដីហើយមានឥទ្ធិពលដល់សរីរាង្គមានជីវិត ដំណើរការនៃការប្រមូលផ្តុំនៃសារជាតិពុលនៅក្នុងសរីរាង្គមានជីវិតអាចចាប់ផ្តើមបង្កផលប៉ះពាល់ដល់សុខភាពមនុស្ស។

ដើម្បីកាត់បន្ថយផលប៉ះពាល់នៃដំណើរការទាំងនេះ គួរពិចារណាចំណុចដូចខាងក្រោម៖

- ប្រតិបត្តិការស្រាវជ្រាវ និងបោសសម្អាតមីនមិនគួរបង្កឱ្យមានសារធាតុពុលនៅក្នុងដី ខ្សែទឹក ឬខ្យល់ច្រើនពេកទេ
- ប្រសិនបើគ្រឿងផ្ទុះមានភាពសឹករិចរិល ឬបាក់បែក គួរធ្វើការស៊ើបអង្កេតសមាសធាតុផ្សំនៃគ្រឿងផ្ទុះ ដើម្បីវាយតម្លៃផលប៉ះពាល់អវិជ្ជមានដែលអាចកើតមានទៅលើដី ខ្សែទឹក និងព្រៃឈើ ហើយត្រូវកំណត់វិធានការកាត់បន្ថយកម្រិតផលប៉ះពាល់
- គួរស្វែងរកជំនួយបច្ចេកទេសសមស្របដើម្បីដោះស្រាយបញ្ហាសារធាតុពុល ដែលមានកម្រិតខ្ពស់នៅក្នុងដី ទឹក និងខ្យល់។

## ៩.៤. ការបំពុលបរិស្ថានដែលបង្កដោយការកម្ទេចគ្រាប់មីននិងស.ផ.ស. និងកាកសំណល់គ្រោះថ្នាក់

គ្រាប់មីននិងស.ផ.ស. ត្រូវកម្ទេចចោលតាមវិធីណាមួយដែលមានផលប៉ះពាល់អប្បបរមាដល់បរិស្ថាន គួរប្រើប្រាស់វិធានការការពារ ប្រសិនបើគ្រាប់មីននិងស.ផ.ស. ត្រូវកម្ទេចនៅនឹងកន្លែង និងមានហានិភ័យដល់បរិស្ថាន (សម្លេង ការរំញ័រដី ការខូចខាតហេដ្ឋារចនាសម្ព័ន្ធ។ល។)។ ទោះបីមានវិធានការការពារហើយក្តី ប្រសិនបើហានិភ័យអវិជ្ជមានដល់បរិស្ថាននៅតែមាន គួរពិគ្រោះយោបល់អំពីប្រតិបត្តិការនោះជាមួយប្រតិបត្តិករសកម្មភាពមីន អាជ្ញាធរមូលដ្ឋាន និងសមាជិកសហគមន៍។

- ការកម្ទេចគ្រាប់មីន និងស.ផ.ស. គួរធ្វើឡើងនៅកន្លែងដែលបានកំណត់ជាមុន ឬក៏ធ្វើឱ្យមានសុវត្ថិភាពអាចចល័តបាន។ ប្រសិនបើមិនអាចចល័តបានទេ ត្រូវកម្ទេចគ្រាប់នេះនៅនឹងកន្លែង។
- បំណែកគ្រាប់ដែលជាប្រភេទលោហៈធាតុ និងរំសេវគួរតែយកចេញ ដើម្បីកុំឱ្យលាយសាយភាយចូលក្នុងខ្សែទឹក។

លើសពីនេះ ដើម្បីចៀសវាងវត្ថុគ្រោះថ្នាក់ប៉ះពាល់តំបន់ដែលមានសុវត្ថិភាព ប្រតិបត្តិករបោសសម្អាតមីនគួរតែ៖

- ហាមឃាត់ការចល័តគ្រាប់មីន និងស.ផ.ស. ចេញពីការដ្ឋាន លើកលែងតែការចល័តនោះបម្រើឱ្យការកម្ទេច ឬសកម្មភាពដែលមានការអនុញ្ញាត
- រក្សាសុវត្ថិភាពគ្រាប់មីនឬស.ផ.ស. ដែលត្រូវចល័តពីការដ្ឋានរហូតដល់គ្រាប់ទាំងនោះត្រូវ បានកម្ទេចចោល
- ធ្វើការពិនិត្យឱ្យបានហ្មត់ចត់នូវគ្រាប់មីននិងស.ផ.ស. និងសម្ភារទុកដាក់នានាដែលបានយកចេញពីការដ្ឋានសម្រាប់ការបណ្តុះបណ្តាល ស្របតាម CMAS 08 ដើម្បីបញ្ជាក់ថា 'គ្មានរំសេវផ្ទុះ(FFE) និងសារធាតុគ្រោះថ្នាក់'
- ពិនិត្យមើលយ៉ាងហ្មត់ចត់ជុំវិញទីតាំងប្រតិបត្តិការបោសសម្អាតមីនដោយគ្រឿងចក្រ ឬទីតាំងកម្ទេចគ្រាប់ ដើម្បីធានាថាមិនមានគ្រាប់មីនឬស.ផ.ស. ខ្ចាតចេញទៅក្នុងតំបន់ទាំងនោះ។

ប្រសិនបើមានការសាយភាយជាតិផ្ទុះប៉ះពាល់ដល់បរិស្ថាន រំសេវ ឬសំណល់របស់វាអាចបំពុលដល់ដី និងទឹកហើយអាចមានផលប៉ះពាល់យ៉ាងខ្លាំងដល់បរិស្ថាន។ លើសពីនេះទៀត សារធាតុអាសេបស្តុស សារធាតុគីមី និងសារធាតុរាវជម្រុញឆេះ អាចត្រូវបានរកឃើញនៅក្នុងគ្រាប់រ៉ូកែត និងប្រព័ន្ធបំផ្ទុះ។ ជាមួយគ្នានេះអាវុធគីមីដែលអាចរកឃើញ ក្នុងនោះមានគ្រាប់បែក ក្លរីន និងឧស្ម័ន Mustard និងគ្រាប់ធ្វើពីលោហៈសំណល់អ៊ុយរ៉ាញ៉ូម ក៏អាចជាបញ្ហាប្រឈមផងដែរ។

ឧទាហរណ៍ផ្សេងទៀតនៃកាកសំណល់ដែលមានសារធាតុពុល និងគ្រោះថ្នាក់រួមមាន៖

- សារធាតុងាយឆេះ កាកសំណល់ខ្លាញ់ ប្រេងរំអិល តម្រងប្រេងឥន្ទនៈ(FOL)
- ថ្មពិល
- កាកសំណល់វេជ្ជសាស្ត្រ ថ្នាំពេទ្យចាស់ៗ និងសារធាតុគីមីដទៃទៀត។

កាកសំណល់ដែលមានសារធាតុពុល និងគ្រោះថ្នាក់ដែលបង្កដោយប្រតិបត្តិការបោសសម្អាតមីន មិនត្រូវយកទៅកប់នៅក្នុងការដ្ឋាន ប៉ុន្តែត្រូវប្រមូល រក្សាទុក ដឹកជញ្ជូនទៅចោលនៅកន្លែងដែលមានការព្រមព្រៀងពីមន្ទីរបរិស្ថានខេត្ត។

## ឧ.៥ . ការបំពុលបរិស្ថានពីការដឹកជញ្ជូនសម្ភារដែលមានសារធាតុគ្រោះថ្នាក់

ក្នុងអំឡុងពេលដឹកជញ្ជូនសម្ភារដែលមានសារធាតុគ្រោះថ្នាក់ សារធាតុពុល ឬសារធាតុងាយឆាបឆេះដែលអាចបំផ្លាញបរិស្ថាន ត្រូវមានវិធានការប្រុងប្រយ័ត្នដើម្បីធានាថា ហានិភ័យត្រូវបានកាត់បន្ថយមកនូវកម្រិតអប្បបរមា។ វិធានការទាំងនេះ រាប់បញ្ចូលទាំង៖

- សម្ភារទាំងអស់ដែលត្រូវដឹកជញ្ជូន ត្រូវដាក់នៅក្នុងកុងតឺន័រដែលអាចកាត់បន្ថយ ឬការពារការកំពប់ ឬលេចធ្លាយ មកនៅកម្រិតអប្បបរមា
- ផ្ទុកសម្ភារក្នុងមធ្យោបាយដឹកជញ្ជូនដោយសុវត្ថិភាព
- យកចិត្តទុកដាក់ និងការពារអគ្គីភ័យចំពោះសម្ភារដែលត្រូវដឹកជញ្ជូន
- បើកបរយានយន្តដែលមានដឹកសម្ភារគ្រោះថ្នាក់ប្រកបដោយសុវត្ថិភាព និងប្រុងប្រយ័ត្ន
- យានយន្តដែលដឹកជញ្ជូនសម្ភារទាំងនេះត្រូវគោរពតាមបទបញ្ញត្តិជាតិ។

ស្តង់ដាជំពូកទី ៤ ស្តីពី "ការដឹកជញ្ជូន និងការប្រើប្រាស់គ្រឿងផ្ទុះ" ផ្តល់នូវលក្ខណៈជាក់លាក់ និងគោលការណ៍ណែនាំសម្រាប់ការរក្សាទុក ការដឹកជញ្ជូន និងការប្រើប្រាស់គ្រឿងផ្ទុះប្រកបដោយសុវត្ថិភាពដល់ប្រតិបត្តិករបោសសម្អាតមីននៅកម្ពុជា។

## ឧ.៦. ការថយចុះគុណភាពខ្យល់

ត្រូវមានវិធានការទប់ស្កាត់នៅពេលអនុវត្តការស្រាវជ្រាវបច្ចេកទេស និងប្រតិបត្តិការបោសសម្អាតដែលអាចជះឥទ្ធិពលអាក្រក់ដល់គុណភាពខ្យល់។ ក្នុងករណីនេះ ប្រតិបត្តិករបោសសម្អាតមីនគួរដឹងអំពីទីតាំងរបស់សហគមន៍ ស្ថានភាពខ្យល់បក់ទូទៅនៅក្នុងតំបន់ និងកម្លាំងខ្យល់បក់នាំផ្សែង ធូលី និងផ្សែងពុលដល់សហគមន៍មូលដ្ឋាន។ ប្រតិបត្តិករបោសសម្អាតមីន គួរធានាថាផលប៉ះពាល់អវិជ្ជមានដល់សហគមន៍ដែលបណ្តាលមកពីការថយចុះគុណភាពខ្យល់ ត្រូវបានកាត់បន្ថយមកកម្រិតអប្បបរមា។

នៅពេលគុណភាពខ្យល់ថយចុះ អាចប៉ះពាល់ដល់សហគមន៍មូលដ្ឋាន ប្រតិបត្តិករបោសសម្អាតមីនគួរទាក់ទងជាមួយសហគមន៍ និងអាជ្ញាធរមូលដ្ឋាន ដើម្បីពន្យល់ពីកម្រិតនៃផលប៉ះពាល់ និងតម្រូវការជម្លៀសចេញប្រសិនបើចាំបាច់។

នៅពេលដែលមានការរំញ័រដី ឬសម្លេងរំខាន ដែលអាចប៉ះពាល់ដល់សហគមន៍មូលដ្ឋាន គួរអនុវត្ត

វិធានការ ដើម្បីកាត់បន្ថយផលប៉ះពាល់ទាំងនោះ វិធានការទាំងនោះរួមមាន៖

ក. ជ្រើសទីតាំងកម្ទេចឱ្យនៅឆ្ងាយពីតំបន់ដែលមានជម្រករស់នៅ

ខ. កំណត់ទំហំសមស្របនៃការកម្ទេចនីមួយៗ

គ. ប្រើប្រាស់រណ្តៅដើម្បីកាត់បន្ថយសម្លេង

ឃ. ប្រើប្រាស់វិធានការការពារដើម្បីកាត់បន្ថយផលប៉ះពាល់នៃការរំញ័រដី និងសម្លេង

ង. ហាមឃាត់សកម្មភាពកម្ទេច នៅពេលមានលក្ខខណ្ឌឧតុនិយមមិនអំណោយផល ឧទាហរណ៍៖ ពពកទាបអាចបង្កើនសម្លេងរំខានខ្លាំង។

## ខ.៧. ផលប៉ះពាល់លើសត្វព្រៃ និងរុក្ខជាតិ

### ខ.១.៧. សត្វព្រៃ

កិច្ចប្រតិបត្តិការបោសសម្អាតមីន មិនគួរមានផលប៉ះពាល់ជាអវិជ្ជមានដល់សត្វព្រៃទេ។ អាជ្ញាធរមីន និងប្រតិបត្តិករបោសសម្អាតមីន ត្រូវស្វែងយល់អំពីធម្មជាតិដែលត្រូវការពារ ដែលអាចរងឥទ្ធិពលពីកិច្ចប្រតិបត្តិការស្រាវជ្រាវ និងបោសសម្អាត ហើយត្រូវពិចារណាចំណុចដូចខាងក្រោម៖

- ត្រូវដេញសត្វព្រៃមុនពេលកម្ទេចគ្រាប់
- រណ្តៅកម្ទេចគ្រាប់រួច គួរត្រូវបំពេញដីឡើងវិញ ឬទុកចោល ដោយគិតគូរពីប្រយោជន៍សម្រាប់ជម្រកសត្វមួយចំនួន ក៏ដូចជាហានិភ័យនៃសំណឹកដែលអាចកើនឡើង
- កំណត់ពេលវេលាសម្រាប់ប្រតិបត្តិការសកម្មភាពមីន ដើម្បីជៀសវាងការរំខានដល់សត្វព្រៃក្នុងអំឡុងពេលបន្តពូជ/ចាំសំបុក
- កំណត់រយៈពេលក្នុងការកម្ទេចគ្រាប់ ដើម្បីកាត់បន្ថយជាអតិបរមានូវផលប៉ះពាល់អវិជ្ជមានដល់សត្វព្រៃ។

### ខ.២.៧. រុក្ខជាតិ

ការកាត់រុក្ខជាតិទំនងជាមិនអាចជៀសបាន ដើម្បីឱ្យការរាវរកមីនអាចប្រព្រឹត្តទៅបាន។ ទោះជាយ៉ាងនេះក្តី ការកាត់រុក្ខជាតិត្រូវធ្វើក្នុងកម្រិតតិចតួចបំផុត និងអនុលោមតាមបទបញ្ញត្តិជាតិជាធរមាន។ អាជ្ញាធរមីន និងប្រតិបត្តិករបោសសម្អាតមីនគួរពិចារណាដូចខាងក្រោម៖

- បើអាចជៀសវាងបាន រុក្ខជាតិទាំងឡាយដែលលូតលាស់យឺត និងប្រើប្រាស់ដោយសហគមន៍ មិនត្រូវកាត់ក្នុងអំឡុងពេលបោសសម្អាតមីនទេ
- រុក្ខជាតិទាំងឡាយដែលទប់ដីពីការសឹករិចរិល និងការពារពីការហូរច្រោះដី គួរតែរក្សាទុក ជាពិសេសនៅលើជម្រាលភ្នំ តាមបណ្តោយដងអូរ និងផ្លូវបង្ហូរទឹក
- មុននឹងកាត់រុក្ខជាតិគួរពិចារណាថា តើទីតាំងនោះត្រូវយកទៅប្រើប្រាស់ក្នុងគោលបំណងអ្វី បន្ទាប់ពីការបោសសម្អាតរួច( លំនៅដ្ឋាន វាលស្មៅ កសិកម្ម ឬឧស្សាហកម្ម)។

### ខ.៧ .៣.ផលប៉ះពាល់ពីការដុតរុក្ខជាតិ

គួរជៀសវាងការដុតរុក្ខជាតិ ប៉ុន្តែស្ថានភាពរុក្ខជាតិខ្លះអាចល្អប្រសើរឡើងក្រោយពេលមានភ្លើងឆេះ។ ស្ថានភាពព្រៃឈើទាំងនោះគួរត្រូវបានកំណត់មុនពេលដុត។ ខណៈពេលដែលប្រតិបត្តិករបោសសម្អាតមីន និងអ្នកពាក់ព័ន្ធយល់ស្របគ្នាថាត្រូវដុតរុក្ខជាតិ គួរអនុវត្តដូចខាងក្រោម៖

- គួរពិភាក្សា និងឯកភាពគ្នារវាងម្ចាស់ដី ឬអ្នកប្រើប្រាស់ដី សហគមន៍មូលដ្ឋាន និងអាជ្ញាធរមូលដ្ឋាន

អំពីផែនការដុតរុក្ខជាតិ

- ការដុតរុក្ខជាតិ គួរធ្វើឡើងបន្ទាប់ពីការបង្អើលសត្វព្រៃឱ្យរត់ចេញ និងមិនត្រូវដុតរុក្ខជាតិក្នុងអំឡុងពេលសត្វបន្តពូជ
- ពេលដុតរុក្ខជាតិ គួរផ្សព្វផ្សាយឱ្យម្ចាស់ដី ឬអ្នកប្រើប្រាស់ដី និងអាជ្ញាធរមូលដ្ឋានដឹងអំពីប្រភេទមីន/ស.ផ.ស. និងគ្រោះថ្នាក់ផ្សេងៗដែលអាចកើតឡើងបាន(អំបែង រំញ័រ ជាតិពុល ផ្សែង។ល។)
- មិនគួរដុតរុក្ខជាតិពេលយប់ ឬបណ្ដោយឱ្យឆេះដល់ពេលយប់នោះទេ
- ពេលដុតរុក្ខជាតិ គួរមានបុគ្គលិក និងឧបករណ៍ពន្លត់អគ្គីភ័យឱ្យបានគ្រប់គ្រាន់នៅនឹងកន្លែង ដើម្បីគ្រប់គ្រងស្ថានការណ៍នៅពេលចាំបាច់
- គួរពិចារណាស្ថានភាពខ្យល់ និងសំណើមមុនពេលដុតរុក្ខជាតិ
- បុគ្គលិកដែលចូលរួមក្នុងការដុតរុក្ខជាតិ គួរទទួលបានការពន្យល់អំពីផែនការដុត រួមទាំងនីតិវិធីសុវត្ថិភាព។

## ៩.៨. ការបំពុលបរិស្ថានបណ្ដាលមកពីកាកសំណល់នៅតាមការដ្ឋាន

គួរពិចារណាអំពីផលប៉ះពាល់បរិស្ថាន អំឡុងពេលរៀបចំការដ្ឋានបោសសម្អាតមីន និងជុំរុំស្នាក់នៅបណ្ដោះអាសន្ន។

គួរជ្រើសរើសការដ្ឋានបោសសម្អាតមីន និងកន្លែងស្នាក់នៅបណ្ដោះអាសន្ន ដែលកាត់បន្ថយផលប៉ះពាល់ឱ្យនៅតិចតួចបំផុតដល់ដី ខ្សែទឹក រុក្ខជាតិ និងជម្រកសត្វព្រៃ។

ការតាំងជុំរុំស្នាក់នៅបណ្ដោះអាសន្ន គួរពិគ្រោះយោបល់ជាមួយបុរស និងស្ត្រីនៅក្នុងសហគមន៍ ដើម្បីធានាថាការស្នាក់នៅនេះមិនប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់លក្ខខណ្ឌតំបន់ សកម្មភាពសេដ្ឋកិច្ច ឬតម្លៃសង្គម និងវប្បធម៌។

### ៩.៨.១. បន្ទប់ទឹក

កាកសំណល់របស់មនុស្សមិនត្រូវបង្ហូរចូលក្នុងប្រភពទឹក ឬលើផ្ទៃដីឡើយ។ ក្នុងករណីដែលអាចធ្វើបាន បន្ទប់ទឹកបណ្ដោះអាសន្នគួរសង់នៅតាមការដ្ឋានបោសសម្អាតមីន និងជុំរុំស្នាក់នៅបណ្ដោះអាសន្នដោយគិតគូរពីតម្រូវការរបស់បុរស និងស្ត្រី។

បង្គន់មួយគួរប្រើប្រាស់សម្រាប់មនុស្សយ៉ាងច្រើន ២០នាក់។ បង្គន់គួរត្រូវបានសាងសង់ស្ថិតនៅចម្ងាយយ៉ាងតិច ៦ម៉ែត្រពីកន្លែងស្នាក់នៅ ឬកន្លែងរៀបចំអាហារ និង២០ម៉ែត្រពីប្រភពទឹក ឬអណ្ដូងទឹក។

### ៩.៨.២. សំរាម

សំរាមដែលយកចេញពីការដ្ឋាន គួរបោះចោលនៅកន្លែងចាក់សំរាមដែលបានកំណត់ និងគួរកប់នៅទីតាំងដែលមានការឯកភាពពីសហគមន៍/អាជ្ញាធរមូលដ្ឋាន។

គួរជ្រើសរើសទីតាំងរណ្ដៅសំរាមឱ្យនៅឆ្ងាយពីផ្លូវទឹក និងអណ្ដូង ហើយរណ្ដៅដែលត្រូវជីកកុំឱ្យប៉ះពាល់/បំពុលទឹកក្រោមដី។

មិនគួរកប់កាកសំណល់ដែលមានសារធាតុគ្រោះថ្នាក់ (ឧទាហរណ៍៖ ផលិតផលប្រេងឥន្ធនៈ លោហៈធាតុគ្រោះថ្នាក់ជាដើម) ក្នុងដី។

### ៩.៨.៣. ទឹកសំណល់

ប្រសិនបើគ្មានប្រព័ន្ធគ្រប់គ្រងទឹកសំណល់ (ទឹកបោកគក់ ទឹកងូត ឬទឹកពីផ្ទះបាយ) គួរបង្ហូរទឹកសំណល់ទាំងនេះចូលរណ្តៅដែលមានទំហំសមរម្យ។ រណ្តៅទឹកសំណល់នេះគួរស្ថិតនៅឱ្យឆ្ងាយពីប្រភពទឹក និងអណ្តូង។

## ៩.៩. ការផ្គត់ផ្គង់ និងប្រើប្រាស់ទឹកក្នុងមូលដ្ឋាន

ការផ្គត់ផ្គង់ និងប្រើប្រាស់ទឹកក្នុងមូលដ្ឋាន គួរធ្វើយ៉ាងណាជៀសវាងការប៉ះពាល់ដល់ការប្រើប្រាស់ទឹករបស់សហគមន៍ លើកលែងតែទទួលបានការយល់ព្រមពីពួកគាត់។

## ៩១.០. ទីតាំងប្រើប្រាស់ប្រេង) ប្រេងឥន្ធនៈ ប្រេង និងប្រេងរំអិល(

ការប្រើប្រាស់ ជួសជុល និងថែទាំឧបករណ៍បោសសម្អាតមីន គួរអនុវត្តយ៉ាងណាដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងអនុលោមតាមបទបញ្ញត្តិជាតិជាធរមាន។

ប្រតិបត្តិការបោសសម្អាតមីនគួរមាននីតិវិធីដើម្បីទុកដាក់ និងសម្អាតពេលប្រេងកំពប់ភ្លាមៗ។ គួរប្រមូលរបស់ (ក្រណាត់ ក្រដាស់ កេសជាដើម) ដែលប្រឡាក់ប្រេង ទៅបោះចោលនៅកន្លែងចាក់សំរាម។

ប្រសិនបើចាំបាច់គួរបង្កើតកន្លែងស្តុកប្រេង និងចាត់វិធានការដើម្បីធានាសុវត្ថិភាពក្នុងការរក្សាទុកប្រេង និងមិនបំពុលដី ឬទឹកក្រោមដី។ វិធានការទាំងនេះរួមមាន៖

- ហាមដាក់ទីតាំងកន្លែងស្តុកប្រេងស្ថិតនៅតិចជាង ៣០ ម៉ែត្រពីប្រភពទឹក
- ត្រូវត្រួតពិនិត្យធុងស្តុក និងឧបករណ៍ផ្ទេរប្រេងទាំងអស់ជាប្រចាំ ដើម្បីធានាថាមិនមានការលេចធ្លាយ
- ការចាក់ប្រេងយានយន្ត និងឧបករណ៍ផ្សេងទៀតត្រូវបានធ្វើឡើងលើផ្ទៃរឹង ឬប្រើប្រាស់ថាសត្រងដើម្បីធានាថាប្រេងដែលកំពប់ត្រូវបានទុកដាក់ និងចាក់ចោលដោយមិនប៉ះពាល់ទៅលើបរិស្ថាន។

## ៩១.១. ទីតាំងថែទាំ និងជួសជុល

ប្រសិនបើការថែទាំ ជួសជុល ឬលាងសម្អាតយានយន្ត ម៉ាស៊ីន និងឧបករណ៍ផ្សេងៗនៅការដ្ឋានជាការចាំបាច់ ត្រូវមានទីតាំងមួយដាក់លាក់សម្រាប់ការងារទាំងនេះ។ វិធានការការពារបរិស្ថានដែលគួរអនុវត្តរួមមាន៖

- មិនត្រូវបង្ហូរទឹកសំណល់ចូលប្រភពទឹក
- ប្រេងដែលប្តូរចោលត្រូវប្រើថាសត្រងសម្រាប់ផ្ទុក ឬឧបករណ៍សមរម្យផ្សេងទៀត ហើយត្រូវទុកដាក់ និងចាក់ចោលដោយមិនប៉ះពាល់ទៅលើបរិស្ថាន
- គ្រឿងបន្លាស់ប្រើប្រាស់រួច ឬសំរាមផ្សេងទៀត (លើកលែងប្រេងដែលប្តូរចោល) ត្រូវបោះចោលដូចសំរាមផ្សេងទៀត។

## ៩.១២. ពេលបញ្ចប់ប្រតិបត្តិការបោសសម្អាតមីន

ពេលបញ្ចប់ប្រតិបត្តិការបោសសម្អាតមីន គួរប្រមូលយកចេញនូវ សំណង់នានា ឧបករណ៍ សម្ភារលើកលែងតែស្លាកសញ្ញាសម្គាល់កន្លែងដែលមិនទាន់បោសសម្អាតផ្សេងទៀត។ រណ្តៅបង្គន់ រណ្តៅទឹកកខ្វក់ និងរណ្តៅសំរាមគួរចាក់ដីបំពេញ ដើម្បីការដុះឡើងវិញនៃរុក្ខជាតិ និងការពារការហូរច្រោះ។

ប្រសិនបើសម្ភារ ឬឧបករណ៍មួយចំនួនដែលយើងលែងត្រូវការ ប៉ុន្តែសហគមន៍អាចប្រើប្រាស់បាន យើងគួរប្រគល់សម្ភារ និងឧបករណ៍ទាំងនោះជូនពួកគាត់។

គួរសម្អាតតំបន់រដ្ឋបាល និងតំបន់បោសសម្អាតមីន/គ្រាប់រួច ដោយយកចេញសម្ភារ ឧបករណ៍ដែលប្រើប្រាស់រួច និងសំណល់អំបែងគ្រាប់ផ្សេងៗ។ នៅពេលដែលមានឱកាសគួរលើកកម្ពស់ ឬផ្តល់នូវផលប្រយោជន៍បរិស្ថាន (ឧទាហរណ៍៖ ដាំដើមឈើ ធ្វើឱ្យប្រសើរឡើងនូវជម្រកសត្វព្រៃ)។

នៅពេលប្រតិបត្តិការកម្ទេចគ្រាប់ត្រូវបានបញ្ចប់ ទីតាំងតំបន់ដែលបានប្រើប្រាស់គួរត្រូវបានកែលម្អស្របតាមលក្ខខណ្ឌតម្រូវនៃស្តង់ដា និងពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន និងសហគមន៍។ ប្រសិនបើចាំបាច់ ដីដែលបានប្រើប្រាស់សម្រាប់ប្រតិបត្តិការបំផ្ទុះអាចត្រូវបានផ្ទេរប្រគល់ជាផ្លូវការ។

## ខ១.៣. ហានិភ័យដល់បេតិកភណ្ឌវប្បធម៌ ឬប្រវត្តិសាស្ត្រ

ការអនុវត្តសកម្មភាពមីននៅទីតាំងតំបន់វប្បធម៌ ឬប្រវត្តិសាស្ត្រ ប្រតិបត្តិករបោសសម្អាតមីនគួរចាត់វិធានការការពារការខូចខាតដល់ទីតាំងបេតិកភណ្ឌទាំងនេះ ។

គ្រាប់មីនឬស.ផ.ស. ដែលបានរកឃើញនៅក្នុងការដ្ឋានប្រតិបត្តិការ យើងត្រូវចល័តគ្រាប់ទាំងនេះទៅទីតាំងផ្សេងដើម្បីកំទេចចោល។ ប្រសិនបើគ្រាប់ទាំងនេះមិនមានសុវត្ថិភាពក្នុងការចល័តទៅទីតាំងផ្សេង ហើយត្រូវកំទេចចោលនៅនឹងកន្លែង គួរអនុវត្តវិធានការការពារដ៏សមស្រប។

ប្រសិនបើរកឃើញវត្ថុនៅក្នុងអំឡុងពេលប្រតិបត្តិការ ហើយសង្ស័យជាវត្ថុបុរាណ គួរផ្អាកប្រតិបត្តិការបណ្តោះអាសន្ន និងរាយការណ៍ទៅអាជ្ញាធរពាក់ព័ន្ធ។

# ឧបសម្ព័ន្ធ គៈ គោលការណ៍ណែនាំសម្រាប់វាយតម្លៃផលប៉ះពាល់បរិស្ថាន

## គ.១. ប្រើប្រាស់ការវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA

ការវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA គឺជាឧបករណ៍សំខាន់ក្នុងការសិក្សាអំពីផលប៉ះពាល់បរិស្ថាន និងដើម្បីធ្វើការសម្រេចចិត្តក្នុងការចាត់វិធានការណ៍ការពារ និងការកាត់បន្ថយផលប៉ះពាល់ ដែលតម្រូវដោយច្បាប់ជាតិស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ។ ជាមួយគ្នានេះ វាក៏អាចជួយសម្រួលដល់ការសហការជាមួយសហគមន៍មូលដ្ឋាន និងភាគីពាក់ព័ន្ធផ្សេងទៀត។ ការវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA គឺជាដំណើរការផ្លូវការ និងគ្រប់ជ្រុងជ្រោយមួយ ក្នុងការផ្តល់ទំនុកចិត្តដល់ភាគីពាក់ព័ន្ធថា រាល់ទិដ្ឋភាពបរិស្ថានដែលពាក់ព័ន្ធត្រូវបានកំណត់ និងវាយតម្លៃត្រឹមត្រូវ ព្រមទាំងមានវិធានការកាត់បន្ថយផលប៉ះពាល់សមស្រប និងប្រកបដោយប្រសិទ្ធភាព។ រាល់ប្រតិបត្តិការបោសសម្អាតមីន ការធ្វើការវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA អាស្រ័យទៅលើទំហំ តម្លៃ ឋេរវេលានៃប្រតិបត្តិការ ឬចំងាយនៃទីតាំងប្រតិបត្តិការទៅតំបន់បរិស្ថាន ដែលអាចទទួលផលប៉ះពាល់ខ្លាំង។ ស្ថាប័នទាំងអស់នៅក្នុងវិស័យមីន ត្រូវបានលើកទឹកចិត្តឱ្យយល់ច្បាស់ពីវិធីសាស្ត្រក្នុងការវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA និងប្រកាន់ខ្ជាប់គោលការណ៍សមស្របក្នុងការការពារបរិស្ថាន នៅតាមការដ្ឋានប្រតិបត្តិការសកម្មភាពមីន។

## គ.២. សម្រាប់អាជ្ញាធរមីន

អាជ្ញាធរមីនត្រូវធានាថា ការវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាព ដើម្បីកំណត់លក្ខខណ្ឌតម្រូវ និងគោលដៅនានាសម្រាប់ប្រតិបត្តិករសកម្មភាពមីន ដើម្បីការពារបរិស្ថាន និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានដែលអាចកើតឡើង។ បញ្ជីត្រួតពិនិត្យខាងក្រោមផ្តល់នូវចំណុចសំខាន់ៗដែលអាជ្ញាធរមីនគួរយកចិត្តទុកដាក់ក្នុងការបំពេញនូវទំនួលខុសត្រូវរបស់ខ្លួន៖

❖ ការងារបឋម៖

- កំណត់ឯកសារគោលនយោបាយ និងច្បាប់បរិស្ថាននៅថ្នាក់ជាតិ និងអន្តរជាតិដែលអាចមាន

ឥទ្ធិពលលើប្រតិបត្តិការស្រាវជ្រាវ និងការបោសសម្អាត

- ធ្វើការសិក្សាលើឯកសារនានាស្តីពីទិដ្ឋភាពបរិស្ថាននៃតំបន់ដែលមាន SHA និង CHA
- កំណត់លក្ខខណ្ឌ និងគោលដៅសម្រាប់ការពារបរិស្ថាន និងការរៀបចំវិធានការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន
- កំណត់ភាគីពាក់ព័ន្ធកម្រិតមូលដ្ឋានជាតិ និងអន្តរជាតិដែលយកចិត្តទុកដាក់ទៅលើទំនាក់ទំនងការបោសសម្អាតមីន និងបរិស្ថាន

- កំណត់ប្រភពសម្រាប់ការកសាងសមត្ថភាពបន្ថែម ឬថវិកា ដើម្បីឆ្លើយតបទៅនឹងបញ្ហាបរិស្ថាន។

❖ ការងារទីវាលៈ

- ប្រសិនបើចាំបាច់ អាជ្ញាធរមីនគួរកំណត់ និងសម្របសម្រួលការចាត់តាំងមន្ត្រីជំនាញពីស្ថាប័នផ្សេងដើម្បីអនុវត្តការវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA នៅទីវាល
- ធ្វើការសាកសួរភាគីពាក់ព័ន្ធ និងសមាជិកសហគមន៍មូលដ្ឋានរួមទាំងបុរស និងស្ត្រីពីក្រុមផ្សេងៗគ្នា អំពីកង្វល់ផលប៉ះពាល់បរិស្ថាន
- កំណត់ជនបង្គោលសម្រាប់ទំនាក់ទំនង (PoC) ក្នុងចំណោមអ្នកពាក់ព័ន្ធ
- បំពេញបន្ថែមការអនុវត្តការវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA ជាមួយនឹងចំណេះដឹង និងព័ត៌មានដែលបានមកពីអ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន
- ពិនិត្យមើលសុពលភាពនៃលទ្ធផលនៃការសិក្សាលើឯកសារនានា

- ពិនិត្យមើលសុពលភាពនៃលក្ខខណ្ឌតម្រូវដែលបានស្នើ និងលទ្ធភាពនៃការសម្រេចបាននៃគោលដៅ។

❖ ការដាក់ភារកិច្ច ឬការដាក់ដេញថ្លៃគម្រោងៈ

- ឯកសារគោលនយោបាយ និងច្បាប់ពាក់ព័ន្ធត្រូវផ្តល់ជូនសម្រាប់អ្នកទទួលភារកិច្ចអនុវត្តការងារ ឬអ្នកចូលរួមដេញថ្លៃ
- ការដាក់ភារកិច្ច ឬការដាក់ដេញថ្លៃគម្រោង ត្រូវបញ្ជាក់លក្ខខណ្ឌតម្រូវនានាក្នុងការការពារបរិស្ថានដែលបានកំណត់នៅក្នុងឯកសារវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA
- ឯកសារនៃការដាក់ភារកិច្ច ឬឯកសារនៃការដាក់ដេញថ្លៃគម្រោង ត្រូវបញ្ជាក់ពីគោលដៅសម្រាប់ការការពារបរិស្ថាន ដែលបានកំណត់នៅក្នុងឯកសារវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA
- លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសអ្នកចូលរួមដេញថ្លៃ គួរមានការវាយតម្លៃអំពីសមត្ថភាពរបស់ប្រតិបត្តិករដេញថ្លៃ ក្នុងការបំពេញលក្ខខណ្ឌនានា និងគោលដៅដែលបានកំណត់នៅក្នុងឯកសារវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA
- ប្រតិបត្តិករដែលបានទទួលភារកិច្ច ឬជោគជ័យក្នុងការដេញថ្លៃ ត្រូវផ្តល់ផែនការការពារបរិស្ថាន និងការកាត់បន្ថយផលប៉ះពាល់ និងឯកសារពាក់ព័ន្ធផ្សេងទៀត(គោលការណ៍ និងនីតិវិធីប្រតិបត្តិការ) មកអាជ្ញាធរមីន
- រាល់ទំនួលខុសត្រូវនៃការអនុវត្តការងារ ពាក់ព័ន្ធនឹងផលប៉ះពាល់បរិស្ថាន ត្រូវតែជាផ្នែកមួយក្នុងឯកសារនៃការដាក់ភារកិច្ច ឬការដេញថ្លៃគម្រោង។

❖ ការត្រួតពិនិត្យ និងការវាយតម្លៃក្នុងកំឡុងពេលប្រតិបត្តិការសកម្មភាពមីនៈ

- ត្រួតពិនិត្យវឌ្ឍនភាពក្នុងការបំពេញគោលដៅ និងអនុលោមភាពតាមលក្ខខណ្ឌតម្រូវដែលបានកំណត់នៅក្នុងការវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA
- ការវាយតម្លៃត្រូវបានអនុវត្តដោយពិចារណាលើលក្ខខណ្ឌតម្រូវ និងគោលដៅដែលបានកំណត់នៅក្នុងការវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA
- ផ្តល់ការពន្យល់ និងយោបល់នានាស្តីពីការការពារបរិស្ថានដល់ប្រតិបត្តិករសកម្មភាពមីន បន្ទាប់ពីការចុះត្រួតពិនិត្យ
- បន្ទាប់ពីការត្រួតពិនិត្យបានបញ្ចប់ គួរធ្វើការវាយតម្លៃទីវាលទៅតាមតម្រូវការជាក់ស្តែង ដើម្បីវាយតម្លៃពីលក្ខខណ្ឌតម្រូវ និងគោលដៅដែលបានកំណត់ក្នុងឯកសារវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA ។

❖ ការរៀបចំឯកសារៈ

- រៀបចំទុកដាក់ឯកសារ និងកំណត់ត្រានានាស្តីពីលក្ខខណ្ឌតម្រូវ និងគោលដៅក្នុងការការពារបរិស្ថាន រួមទាំងចំណុចសំខាន់ៗដែលបានរកឃើញក្នុងពេលវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA ឱ្យបានត្រឹមត្រូវ
- កត់ត្រាឧបទ្ទវហេតុបរិស្ថានដែលកើតឡើង ទុកជាឯកសារឱ្យបានត្រឹមត្រូវ
- រៀបចំទុកដាក់ឯកសារ និងកំណត់ត្រាបទពិសោធន៍ល្អៗ ព្រមទាំងការអនុវត្តល្អ/ឧត្តមានុវត្តនានាផងដែរ
- រៀបចំទុកដាក់ឯកសាររបស់ប្រតិបត្តិករសកម្មភាពមីន (ផែនការការងារ គោលនយោបាយ និងនីតិវិធីប្រតិបត្តិការ) ឱ្យបានត្រឹមត្រូវ។

## គ.៣. សម្រាប់ប្រតិបត្តិករសកម្មភាពមីន

ប្រតិបត្តិករសកម្មភាពមីនត្រូវអនុវត្តការងារប្រតិបត្តិការទៅតាមលក្ខខណ្ឌតម្រូវ និងគោលដៅដែលបានកំណត់ដោយការវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA ។ ភាគីពាក់ព័ន្ធទាំងអស់ត្រូវស្វែងយល់ និងឯកភាពទៅលើលក្ខខណ្ឌតម្រូវ ដើម្បីចងក្រងជាឯកសារសម្រាប់ការអនុវត្តការងារ។ ដើម្បីបំពេញនូវទំនួលខុសត្រូវប្រតិបត្តិករគួរយកចិត្តទុកដាក់ទៅលើចំណុចសំខាន់ៗដូចខាងក្រោមៈ

❖ ការអនុវត្តការងារ ឬការចូលរួមដេញថ្លៃគម្រោងៈ

- លក្ខខណ្ឌតម្រូវ និងគោលដៅសម្រាប់ការការពារបរិស្ថាន នៅក្នុងការអនុវត្តការងារនិងការចូលរួមដេញថ្លៃគម្រោង គឺផ្អែកលើការវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA
- ត្រូវស្វែងយល់លក្ខខណ្ឌតម្រូវ និងគោលដៅ និងរៀបចំឯកសារនានាឱ្យបានច្បាស់លាស់ (គោលនយោបាយ ច្បាប់ និងចំណុចសំខាន់ៗរកឃើញក្នុងពេលវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA)។ ប្រសិនបើមិនយល់ច្បាស់ ឬមិនមានឯកសារគ្រប់គ្រាន់ ត្រូវស្នើសុំការពន្យល់ និងឯកសារពាក់ព័ន្ធ
- ត្រូវត្រៀមឯកសារផ្ទៃក្នុងស្តីពីការការពារបរិស្ថានឱ្យបានរួចរាល់ និងផ្តល់ជូនអាជ្ញាធរមីន (គោលនយោបាយ នីតិវិធីប្រតិបត្តិការ និងផែនការការងារ)
- ដាក់ជូនផែនការការពារ និងការកាត់បន្ថយផលប៉ះពាល់បរិស្ថាន ដែលបញ្ជាក់ថាស្ថាប័នអ្នកអាចឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវ និងសម្រេចគោលដៅដែលបានចែងនៅក្នុងការវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA។

- ❖ ការធ្វើផែនការ៖
  - ធានាថាសមត្ថភាព និងការយល់ដឹងអំពីការការពារបរិស្ថានស្របទៅនឹងលក្ខខណ្ឌតម្រូវ និងគោលដៅដែលបានកំណត់នៅក្នុងឯកសារវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA
  - ធានាថាផែនការដែលបានរៀបចំ ឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវ ដែលបានចែងនៅក្នុងឯកសារវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA
  - ចូលរួមផ្តល់យោបល់ជាបទពិសោធន៍ និងឧត្តមានុវត្តដល់អាជ្ញាធរមីន ក្នុងការឆ្លើយតបទៅនឹងលក្ខខណ្ឌតម្រូវ និងគោលដៅសម្រាប់ការការពារបរិស្ថាន។
- ❖ ការតាមដាន និងវាយតម្លៃ៖
  - លក្ខខណ្ឌតម្រូវ និងគោលដៅដែលកំណត់ដោយការវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA ដែលបញ្ជាក់នៅក្នុងឯកសារដេញថ្លៃ កិច្ចសន្យា បទបញ្ជាភារកិច្ច ឬផែនការការងារ ត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធគ្រប់គ្រងគុណភាពផ្ទៃក្នុង (QMS)
  - ចាត់តាំងជនបង្គោលទទួលខុសត្រូវលើការអនុវត្តលក្ខខណ្ឌតម្រូវ និងគោលដៅសម្រាប់ការការពារបរិស្ថាន
  - ដាក់បញ្ចូលព័ត៌មានពាក់ព័ន្ធការការពារបរិស្ថានក្នុងប្រព័ន្ធរាយការណ៍។
- ❖ ការរៀបចំឯកសារ៖
  - រៀបចំទុកដាក់ឯកសារគោលនយោបាយ និងឯកសារច្បាប់ដែលផ្តល់ដោយអាជ្ញាធរមីន ឱ្យបានត្រឹមត្រូវ
  - រៀបចំទុកដាក់ឯកសាររបាយការណ៍ស្តីពីការការពារបរិស្ថានឱ្យបានត្រឹមត្រូវ
  - រៀបចំទុកដាក់ឯកសារ និងកំណត់ត្រាបទពិសោធន៍ល្អៗ ព្រមទាំងឧត្តមានុវត្តនានា ឱ្យបានត្រឹមត្រូវ។

## ឧបសម្ព័ន្ធ ឃៈ (ព័ត៌មាន) បញ្ជីត្រួតពិនិត្យការគ្រប់គ្រងបរិស្ថាន

បញ្ជីត្រួតពិនិត្យខាងក្រោមសម្រាប់ប្រើប្រាស់ជាជំនួយសម្រាប់អ្នកគ្រប់គ្រងការដ្ឋាន និងបុគ្គលិកប្រតិបត្តិការ ដើម្បីបញ្ជាក់ថារាល់ទិដ្ឋភាពបរិស្ថានត្រូវបានឆ្លើយតបគ្រប់ជ្រុងជ្រោយ នៅពេលប្រើប្រាស់ការដ្ឋាន ។

### ឃ.១. ការជ្រើសរើសទីតាំងការដ្ឋាន

- ទីតាំងការដ្ឋានត្រូវបានជ្រើសរើស ដោយពិគ្រោះយោបល់ជាមួយប្រធានសហគមន៍មូលដ្ឋាន(មេឃុំ)
- គួរជ្រើសរើសទីតាំងការដ្ឋានដែលមានស្រាប់ និងមានផ្លូវចូល
- ចៀសវាងតំបន់ដែលងាយប៉ះពាល់ដល់ផលិតភាពកសិកម្ម ឬបរិស្ថាន
- ធានាសុវត្ថិភាព ក្នុងការផ្គត់ផ្គង់ទឹកសម្រាប់បរិភោគ ការបំផ្លាញចោលលាមកនិងទឹកនោមមនុស្ស ទឹកសំណល់ និងសំរាម ការគ្រប់គ្រងសត្វល្អិតនិងសត្វកកេរ ការគ្រប់គ្រងម្ហូបអាហារ និងការរៀបចំកន្លែងបង្ហូរទឹកនៅក្នុងការដ្ឋាន
- ជៀសវាងការឈូសឆាយរុក្ខជាតិដោយគ្រឿងចក្រ ប្រសិនបើអាចគួរកាត់រុក្ខជាតិដោយដៃ ជៀសវាងការរំខានដល់សណ្ឋានដី ឬការគាស់

កកាយ

- ការដ្ឋានត្រូវរៀបចំនៅលើទីតាំងដែលមានសណ្ឋានដីស្តេរភាព មានកន្លែងបង្ហូរទឹកសមស្រប ហើយប្រសិនបើអាចគឺមានជម្រៅដីគ្រប់គ្រាន់សម្រាប់ជីកបង្គន់អនាម័យ រណ្តៅទឹក និងរណ្តៅសំរាម។

**ឃ.២. ការផ្គត់ផ្គង់ទឹក**

- ពេលរៀបចំការដ្ឋានត្រូវចៀសវាងការរំខានដល់ការផ្គត់ផ្គង់ទឹកដល់អ្នកប្រើប្រាស់/ម្ចាស់ដី និងសហគមន៍នៅជិត
- ទឹកដែលបានផ្គត់ផ្គង់ត្រូវមានសុវត្ថិភាពសម្រាប់ការប្រើប្រាស់របស់មនុស្ស។

**ឃ.៣. កាកសំណល់រឹង**

- ត្រូវធ្វើការសម្អាតសំរាម នៅក្នុងតំបន់ការដ្ឋាន
- បុគ្គលិកទាំងអស់ត្រូវបានណែនាំឱ្យបោះចោលសំណល់អាហារ និងកាកសំណល់ផ្សេងទៀតឱ្យបានត្រឹមត្រូវ
- ធុងកាកសំណល់រឹងត្រូវ៖
    - មានទំហំគ្រប់គ្រាន់សម្រាប់ទុកដាក់កាកសំណល់ទាំងអស់នៅក្នុងរយៈពេលសមស្រប
    - មានលក្ខណៈគ្រប់គ្រាន់ក្នុងការញែកកាកសំណល់ដែលងាយឆេះ និងកាកសំណល់ផ្សេងៗ
    - រឹងមាំដែលមិនអាចបំផ្លាញដោយសត្វ និងសត្វល្អិត ជាពិសេសសម្រាប់សត្វកកេរ
    - មានលក្ខណៈគ្រប់គ្រាន់សម្រាប់ផ្ទុកអង្គធាតុរាវ
    - មានជាប្រចាំ
    - ត្រូវយកកាកសំណល់ទៅកែច្នៃ ឬបំផ្លាញចោលនៅកន្លែងចាក់សំរាម ដែលត្រូវបានអនុញ្ញាតិតាមដែលអាចធ្វើទៅបាន និងសម្អាតរាល់សំណល់វត្ថុ ឬសំរាមដែលនៅតាមផ្លូវចូលការដ្ឋាន។
- កាកសំណល់ដែលត្រូវបំផ្លាញចោលនៅការដ្ឋាន៖
    - គួរដុត និងបំផ្លាញចោលកាកសំណល់រឹងងាយឆេះជាប្រចាំនៅក្នុងរណ្តៅដី ចំណែកសំណល់ផេះគួរលុបគ្របពីលើដោយដីបន្ទាប់ពីការដុត ឬការបំផ្លាញចោល
    - គួរទុកដាក់កាកសំណល់ផ្សេងទៀតដោយកប់នៅក្នុងរណ្តៅ និងលុបគ្របពីលើដោយដីជារៀងរាល់ថ្ងៃ
    - រណ្តៅកប់ទាំងអស់ត្រូវមានទីតាំងស្ថិតនៅឆ្ងាយពីប្រភពទឹក ដើម្បីការពារមិនឱ្យសារធាតុពុលហូរចូលទន្លេបឹងបួរ និងប្រព័ន្ធទឹកក្រោមដី។ បាតរណ្តៅត្រូវស្ថិតនៅជម្រៅសមរម្យលើ

ប្រព័ន្ធទឹក

- ត្រូវប្រមូលកាកសំណល់មានសារជាតុពុល ឬគ្រោះថ្នាក់ ទៅកន្លែងបំផ្លាញចោលដែលបានអនុញ្ញាត។

### ឃ.៤. កាកសំណល់មនុស្ស

- មិនត្រូវបង្ហូរកាកសំណល់មនុស្ស ចូលទៅក្នុងប្រភពទឹក ឬលើផ្ទៃដីឡើយ
- ការប្រើប្រាស់បង្គន់អនាម័យគួរពិចារណាចំណុចសំខាន់ដូចខាងក្រោម ៖
    - បង្គន់មួយគួរប្រើប្រាស់សម្រាប់មនុស្សយ៉ាងច្រើន ២០នាក់
    - បង្គន់មានចម្ងាយយ៉ាងតិច ៦ម៉ែត្រពីកន្លែងស្នាក់នៅ ឬកន្លែងរៀបចំអាហារ និងយ៉ាងហោចណាស់ ២០ម៉ែត្រពីផ្លូវទឹក អណ្តូង ឬប្រភពទឹកបរិភោគផ្សេងទៀត
    - ទឹកប្រើប្រាស់លើផ្ទៃដីគួរបង្ហូរចេញឱ្យឆ្ងាយ និងមិនហូរចូលក្នុងរណ្តៅ

- បាចកំបោរជាប្រចាំ។

D

### ឃ.៥. ការគ្រប់គ្រងទឹកសំណល់

- ត្រូវបង្ហូរទឹកសំណល់ពីទឹកបោកគក់ ទឹកងូត និងទឹកផ្ទះបាយ ទៅក្នុងរណ្តៅសំណល់ទឹក លើកលែងតែចំនួនទឹកមានបរិមាណតិចតួច
- មិនត្រូវបង្ហូរទឹកសំណល់ចូលក្នុងប្រភពទឹក ឬបង្គន់អនាម័យទេ
- រណ្តៅទឹកសំណល់ត្រូវ៖
    - មានទំហំធំល្មមគ្រប់គ្រាន់ដើម្បីផ្ទុកបរិមាណទឹកដែលបានប្រើប្រាស់
    - រៀបចំឱ្យមានសុវត្ថិភាពដោយដាក់របាំងនៅជុំវិញគែមរណ្តៅ
    - ដាក់ថ្នាំសំលាប់មេរោគឱ្យបានទៀងទាត់។

### ឃ.៦. ពេលបញ្ចប់ប្រតិបត្តិការ

- ត្រូវយកចេញទាំងស្រុងរាល់សម្ភារការដ្ឋាន និងហេដ្ឋារចនាសម្ព័ន្ធស្នាក់នៅ សម្រាប់ការដ្ឋានបោសសម្អាតមីនដូចជា អាគារ គ្រឿងបរិក្ខា និងវត្ថុផ្សេងទៀត
- ចាក់ដីលុបបំពេញបង្គន់អនាម័យ រណ្តៅទឹកសំណល់ និងរណ្តៅចាក់សំរាមឱ្យស្មើផ្ទៃដីខាងលើ ដើម្បីការពារការហូរច្រោះ និងទុកឱ្យស្មៅ/រុក្ខជាតិធម្មជាតិដុះឡើងវិញ
- ត្រូវរុះរើសម្ភារបើកផ្លូវ លូរបណ្តោះអាសន្ន និងបណ្តាញខ្សែទឹកកប់នានា ដើម្បីឱ្យទីតាំងការដ្ឋានមានស្ថានភាពស្រដៀងស្ថានភាពមុនប្រតិបត្តិការ

- លំនាំបង្ហូរទឹកដើមត្រូវបានរៀបចំឡើងវិញ
- តាមដែលអាចធ្វើទៅបាន តំបន់ដែលទទួលរងការប៉ះពាល់ទាំងអស់គួរត្រូវបានស្តារឡើងវិញឱ្យដូចស្ថានភាពដើម ឬស្រដៀងគ្នា។